ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៧ លេខ ០៩ ត្រីមាសទី ០១ ឆ្នាំ ២០១៧

# រាជកិច្ច

ផ្សាយចេញពី

## ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៦-០១-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០១១៧/០៧៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេនា ចំពោះ អស់លោក និងលោកស្រី ចំនួន ១៦ រូប ៨០៦

០១-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/០៨៦ ស្ដីពី ការដាក់លោក **ត ស៊ីជេត** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសាធារណការ និងដឹកជញ្ជូន ឱ្យចូលនិវត្តន៍មុនអាយុកំណត់ តាមការស្នើសុំរបស់សាមីខ្លួន ៨០៧

០១-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/០៨៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះព្រះតេជគុណ លោកជំទាវ ឧបាសក និងអស់លោក ចំនួន ០៨ អង្គ/រូប ៨០៨

០១-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/០៨៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម អស់លោក និងលោកស្រី ចំនួន ៨៤ រូប ៨០៩

០១-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/០៨៩ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់កញ្ញា **ស៊ែហេង រតនា** (SAE-HENG RATTANA) ជនជាតិថៃ សញ្ជាតិថៃ ៨១២

០១-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/០៩០ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **លាវ ហ៊្វុយឈី** (LIU HUI-CHI) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិន តៃវ៉ាន់ ៨១៣

០១-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/០៩១ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **គួ ពីងសៀន** (KUO PING-HSIEN) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិន តៃវ៉ាន់ ៨១៤

០១-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/០៩២ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **វង្ស ឌីងខាយ** (WANG DINGKAI) ជនជាតិចិន សញ្ជាតិចិន ៨១៥

០១-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/០៩៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់កញ្ញា **លីន ហាវ អ៊ី** (LIN HAO-YI) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ៨១៦

## II~ក្រុមប្រឹក្សាធម្មនុញ្ញ

០២-០២-២០១៧ -សេចក្តីសម្រេចលេខ ១៦៤/០០៤/២០១៧ កបធ.ច ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៧ លើសំណុំរឿងលេខ ៣២៣/០៦១/២០១៧ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧ ៨១៧

០២-០២-២០១៧ -សេចក្តីសម្រេចលេខ ១៦៥/០០៥/២០១៧ កបធ.ច ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៧ លើសំណុំរឿងលេខ ២៧៤/០១២/២០១៧ សំណុំរឿងលេខ ២៧៥/០១៣/២០១៧ និងសំណុំរឿងលេខ ២៧៦/០១៤/២០១៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៧ ៨២០

០២-០២-២០១៧ -សេចក្តីសម្រេចលេខ ១៦៦/០០៦/២០១៧ កបធ.ច ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៧ លើសំណុំរឿងលេខ ២៧៧/០១៥/២០១៧ សំណុំរឿងលេខ ២៧៨/០១៦/២០១៧ និងសំណុំរឿងលេខ ២៧៩/០១៧/២០១៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៧ ៨២៥

០២-០២-២០១៧ -សេចក្តីសម្រេចលេខ ១៦៧/០០៧/២០១៧ កបធ.ច ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៧ លើសំណុំរឿងលេខ ២៨០/០១៨/២០១៧ សំណុំរឿងលេខ ២៨១/០១៩/២០១៧ និងសំណុំរឿងលេខ ២៨២/០២០/២០១៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៧ ៨៣០

០៣-០២-២០១៧ -សេចក្តីសម្រេចលេខ ១៦៨/០០៨/២០១៧ កបធ.ច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៧ លើសំណុំរឿងលេខ ២៨៣/០២១/២០១៧ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៧ ៨៣៤

## III~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

០៣-០២-២០១៧ -អនុក្រឹត្យលេខ ១៤ អនក្រ.បក ស្តីពី ការគ្រប់គ្រង និងការកំណត់បៀវត្សប្រចាំខែ និងការឧបត្ថម្ភផ្សេងៗ សម្រាប់មន្ត្រីរាជការ និងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស ៨៣៨

០៦-០២-២០១៧ -អនុក្រឹត្យលេខ ១៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៨៤៧

០២-០២-២០១៧ -អនុក្រឹត្យលេខ ៨៤ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ៨៤៩

០២-០២-២០១៧ -អនុក្រឹត្យលេខ ៨៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៨៥០

០២-០២-២០១៧ -អនុក្រឹត្យលេខ ៨៦ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៨៥១

០២-០២-២០១៧ -អនុក្រឹត្យលេខ ៨៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៨៥២

០២-០២-២០១៧ -អនុក្រឹត្យលេខ ៨៨ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ៨៥៣

០២-០២-២០១៧ -អនុក្រឹត្យលេខ ៨៩ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ៨៥៤

០២-០២-២០១៧ -អនុក្រឹត្យលេខ ៩០ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៨៥៦

០២-០២-២០១៧ -អនុក្រឹត្យលេខ ៩១ អនក្រ.តត ស្តីពី ការតែងតាំងជំនួយការរដ្ឋមន្ត្រី ៨៥៨

០៣-០២-២០១៧ -អនុក្រឹត្យលេខ ៩២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៨៥៩

០៣-០២-២០១៧ -អនុក្រឹត្យលេខ ៩៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៨៦១

០៣-០២-២០១៧ -អនុក្រឹត្យលេខ ៩៤ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ៨៦២

០៣-០២-២០១៧ -អនុក្រឹត្យលេខ ៩៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨៦៣

០៣-០២-២០១៧ -អនុក្រឹត្យលេខ ៩៦ អនក្រ.តត ស្តីពី ការលុបឈ្មោះនាយទាហាន ៨៦៥

០៣-០២-២០១៧ -អនុក្រឹត្យលេខ ៩៧ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិនាយទាហាន ៨៦៦

០៣-០២-២០១៧ -អនុក្រឹត្យលេខ ៩៨ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៨៦៩

០៣-០២-២០១៧ -អនុក្រឹត្យលេខ ៩៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៨៧០

០៣-០២-២០១៧ -អនុក្រឹត្យលេខ ១០០ អនក្រ.តត ស្តីពី ការផ្លាស់ប្តូរ និងតម្លើងឋានន្តរស័ក្តិ មកជានាយក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ និងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៨៧១


## ២-សេចក្តីសម្រេច


០៣-០២-២០១៧ -សេចក្តីសម្រេចលេខ ០៩ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួង រៀបចំកិច្ចប្រជុំតុមូលចិនលើកទី ៥ ៨៧៣


## IV-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៥-០១-២០១៧ -ប្រកាសលេខ ០៣៦ សហវ.ប្រក ស្តីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទានសម្រាប់ឆ្នាំ ២០១៧ របស់អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៨៧៦

៣១-០១-២០១៧ -ប្រកាសលេខ ១០៦ សហវ.ប្រក ស្តីពី ការបង្កើត និងតែងតាំងក្រុមលទ្ធកម្ម នៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ៨៨២

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

៣០-០១-២០១៧ -ប្រកាសលេខ ០៣៦ ព.ណ.គន.ប្រក ស្តីពី ការតែងតាំងអាណាប័កផ្ទេរសិទ្ធិ និងការផ្ទេរឥណទានថវិកា ៨៨៥

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

០៥-០១-២០១៧ -ប្រកាសលេខ ០០២ ឧស.កឧ.ប្រក ០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វ៊ូតម៉ាក (ខេមបូឌា) ខបភើរេសិន បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់កីឡា ៨៨៧

០៥-០១-២០១៧ -ប្រកាសលេខ ០០៣ ឧស.កឧ.ប្រក ០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន តាណាកាហ្វ័រសាយថឺ (ខេមបូឌា) អ៊ីន បង្កើតរោងចក្រ ផលិតសម្ភារៈវ៉ែនតា ៨៩០

១៦-០១-២០១៧ -ប្រកាសលេខ ០១១ ឧស.កឧ.ប្រក ០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អាឡិចថូវៀប៊ីលម៉ាត (ខេមបូឌា) បង្កើតរោងចក្រ ផលិតគ្រឿងសង្ហារឹម ៨៩៣

១៦-០១-២០១៧ -ប្រកាសលេខ ០១២ ឧស.កឧ.ប្រក ០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន នីសសូតូ (ខេមបូឌា) ខូ អិលធីឌី បង្កើតរោងចក្រ ផលិតអាហារបំប៉ន ៨៩៦

១៦-០១-២០១៧ -ប្រកាសលេខ ០១៣ ឧស.កឧ.ប្រក ០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន លូ ថៃ (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨៩៩

១៦-០១-២០១៧ -ប្រកាសលេខ ០១៤ ឧស.កឧ.ប្រក ០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ចាកា ស៊ូមេនូហ្វេកធើរី ខូ អិលធីឌី បង្កើតរោងចក្រ ផលិតស្បែកជើង ៩០២

## ៤-អង្គភាពប្រឆាំងអំពើពុករលួយ

១០-០១-២០១៧ -ប្រកាសលេខ ០០១/១៧ ស.រ អ.ប.ព ស្តីពី ការតែងតាំងអាណាប័កជំនួស ៩០៥

# **ព្រះរាជក្រឹត្យ**

នស/រកត/០១១៧/០៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **អង្គ វង្សវឌ្ឍានា**
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម)

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

**ចំពោះ**

១- លោក **ហួន ម៉ានី**
២- លោក **គាំ ឈាន**
៣- លោក **ខ្លូត ពេជ្រ**
៤- លោក **ថោង អុល**
៥- លោកស្រី **បេ គីមយាង**
៦- លោកស្រី **ស៊ឹម សាម៉ើ**
៧- លោក **សុខ លាង**
៨- លោក **ម៉ក់ តាង**
៩- លោក **ឌុច ចន្ថា**
១០- លោក **គឹម អេង**
១១- លោក **តាយ គង់**
១២- លោក **ចេង ប៊ុនលី**
១៣- លោក **ម្លូង សារិន**
១៤- លោក **ផាត់ ថៃ**
១៥- លោក **ទេព សុខុម**
១៦- លោក **សំ សារុន**

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

៧រ៦ល. ១៧០១.០៧៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៧*

លេខ: ៩៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/០៨៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដាក់ លោក **ត ស៊ីដេត** បាឋន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសាធារណការ និងដឹកជញ្ជូន ឱ្យចូលនិវត្តន៍មុនអាយុកំណត់ តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៦ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ៧. ១៧០៤.០៨៧

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧

លេខៈ ៤៤៧. ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/០៩៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**នូវ**

ក. គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-ព្រះតេជគុណ **នុយ ភារម្យ** ២-លោកជំទាវ **ឯក វណ្ណតារា**
៣-លោក **លី សាវេត** ៤-លោក **មាន សុផាន្នី**

ខ. គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១-លោក **សួន ម៉ុក** ២-ឧបាសក **ឆាវ ហុង**
៣-លោក **អ៊ិច សម្បត្តិ**

គ. គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

ព្រះតេជគុណ **ស៊ូ សុខគា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

តរស.១៧០២.០៩៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ៧០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០២១៧/ ០៨៨

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោធិតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**នូវ**

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា**ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-លោកឧត្តមសេនីយ៍ត្រី **សុខ គីមស៊ីន** អត្តលេខ ៦៨៣២៧
២-លោកស្រីឧត្តមសេនីយ៍ត្រី **ទី សាឌី** អត្តលេខ ០៥៦៣២
៣-លោកវរសេនីយ៍ឯក **សាន ស៊ីណា** អត្តលេខ ៦៨៦៨៩
៤-លោកវរសេនីយ៍ឯក **អេម សម្បត្តិ** អត្តលេខ ០៧៥២០
៥-លោកវរសេនីយ៍ឯក **ជួង សុភា** អត្តលេខ ៦៨៣៦៨
៦-លោកវរសេនីយ៍ទោ **ណាយ សុផារ័ត្ន** អត្តលេខ ៦៨៣៦៤
៧-លោកវរសេនីយ៍ត្រី **ស៊ឹ វ៉េន** អត្តលេខ ៥៦៤៨៥
៨-លោកវរសេនីយ៍ត្រី **ថា សុជាតិ** អត្តលេខ ៦៤៣១៦
៩-លោកវរសេនីយ៍ត្រី **អេម សុវណ្ណារ៉ា** អត្តលេខ ៦៧៥៦៥
១០-លោកវរសេនីយ៍ត្រី **ឌុម ស៊ីដេត** អត្តលេខ ៦៣១០៤
១១-លោកវរសេនីយ៍ត្រី **គួរ ចិន្តា** អត្តលេខ ៦១៣៤២

១២-លោក **គង់ សម្បត្តិ**
១៣-លោក **ឆេង វ៉ាន់ថា**
១៤-លោក **កយ ស្រ៊ី**
១៥-លោក **គី ហាលី**
១៦-លោក **គូ ដាណេ**
១៧-លោកស្រី **ខួន សុចិត្រា**
១៨-លោក **ជន់ មិថុនា**
១៩-លោក **ពីង គីមអាន**
២០-លោក **អ៊ីវ៉ាន សម្ផស្ស**
២១-លោក **លី សុខា**
២២-លោក **ខែត ពិសិដ្ឋ**
២៣-លោក **ឡាង វណ្ណានី**
២៤-លោក **អេម សម្បត្តិបូរ៉ាមី**
២៥-លោក **ជ្រឹន ឈុន**
២៦-លោក **កេត ផាវ៉ែន**
២៧-លោក **ញ៉ៀម រិទ្ធី**
២៨-លោក **ទី វ៉ាន់ដា**
២៩-លោកស្រី **យិត ម៉ារី**
៣០-លោក **សាត សោភ័ណ្ឌ**
៣១-លោក **ស វុត្ថា**
៣២-លោក **ណយ សុតិរុណ**
៣៣-លោក **គង់ ប៉េងលាង**
៣៤-លោក **នួន ណាត**

**ខ.** គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-ឯកឧត្តម **វ៉ា សារ៉េន**
២-លោក **ញ៉ៀម រដ្ឋា**
៣-លោក **អ៊ីន់ សំអាត**
៤-លោក **សន ពិសី**
៥-លោក **គីម លីម៉ា**
៦-លោកវរសេនីយ៍ទោ **យូ ខួនហេង** អត្តលេខ ០៨៨១១
៧-លោកវរសេនីយ៍ត្រី **អ៊ីវាន ចន្ទិកា** អត្តលេខ ៥៥០៣៥

**គ.** គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-លោកឧត្តមសេនីយ៍ទោ **ជី សាន** អត្តលេខ៧៨២២២
២-លោកឧត្តមសេនីយ៍ត្រី **ញ៉ៀម ណារ័ត្ន** អត្តលេខ ០៣០២៤
៣-លោកឧត្តមសេនីយ៍ត្រី **ណយ សុផានរិទ្ធ** អត្តលេខ ៥៥៤០១
៤-លោកវរសេនីយ៍ទោ **ហាស់ ឌីណា** អត្តលេខ ៦៧៨៩២
៥-លោកវរសេនីយ៍ទោ **ឡាយ ចំនួដា** អត្តលេខ ៥៦៥៤៧
៦-លោក **សរ វិចិត្រា**
៧-លោក **យិត ភីរិន**
៨-លោក **លីម ស៊ីផា**
៩-លោក **វ៉ា សុវណ្ណពិសាល**

**ឃ.** គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈ នារីរត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-លោកវរសេនីយ៍ឯក **យិត ភីរៈ** អត្តលេខ ៥៦៤៦៦
២-លោកវរសេនីយ៍ទោ **ឯម កុសល** អត្តលេខ ៦៤៣០៧
៣-លោកវរសេនីយ៍ត្រី **ស៊ី ឡា** អត្តលេខ ៣៣០៧៣
៤-លោក **គង់ ហ៊ុនធារិទ្ធ**
៥-លោក **អាន សុតក្រ**
៦-លោកស្រី **ពេជ្រ បូណាត**
៧-លោកស្រី **កែវ បូព្រឹក**



៨-លោកស្រី **ឡឹក ស៊ីខុនណារ៉ា** ៩-លោក **លឹម សេងហួត**

១០-លោក **ហង្ស ប្រសើរ**

ខ~ គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា**ថ្នាក់ **មហាសេនា** :

១-លោកឧត្តមសេនីយ៍ត្រី **ហួត ស៊ូ** អត្តលេខ ០៨៣៥

២-លោកឧត្តមសេនីយ៍ត្រី **ឆៀវ សុខន** អត្តលេខ ០៨៤០

៣-លោក **លឹម ម៉េងហុង** ៤-លោក **អៀង បូរ៉ា**

៥-លោក **អ៊ុ ស៊ីថាន** ៦-លោក **គីម សំរេច**

៧-លោក **ព្រាំ ទុន្ធី** ៨-លោក **អឿន ឆេងហៃ**

៩-លោក **ស៊ូ ពិសែន** ១០-លោក **ឃិន ប៊ុនធឿន**

១១-លោក **ចាន់ ទិសុទ្ធ** ១២-លោកស្រី **ឃីម ស៊ុនម៉ាលីនីន**

ច~ គ្រឿងឥស្សរិយយស **សុវត្ថារា**ថ្នាក់ **មហាសេនា** :

១-លោកវរសេនីយ៍ទោ **គ្រួច សុផល** អត្តលេខ ១០៦៧២

២-លោកអនុសេនីយ៍ឯក **ចាន់ ប៊ូរី** អត្តលេខ ៦៧៧៣៧

ឆ~ គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

លោក **ទ្រី លាងសេង**

ជ~ គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធិ** :

១-លោកវរសេនីយ៍ឯក **រីវ៉ាន សុគ័ន្ធគ្រា** អត្តលេខ ៥៤៨៩៥

២-លោកវរសេនីយ៍ត្រី **យស់ ចំណាន** អត្តលេខ ០៥៦២៦

៣-លោកវរសេនីយ៍ត្រី **លក្ខណា នីរូជេម** អត្តលេខ ៧២០០៧

៤-លោកវរសេនីយ៍ត្រី **មួន ឌីណា** អត្តលេខ ៥៤៤២៨

៥-លោកវរសេនីយ៍ត្រី **ខៃ សុវណ្ណ** អត្តលេខ ៦៩៥៣៧

៦-លោកវរសេនីយ៍ត្រី **កែវ រតនា** អត្តលេខ ៦៦៧៥៤

៧-លោកវរសេនីយ៍ត្រី **កែវ រ៉េតមុន្នី** អត្តលេខ ៧៥៧២៧

៨-លោកវរសេនីយ៍ត្រី **មុនី សីហា** អត្តលេខ ៥៤៤៣៤

៩-លោកវរសេនីយ៍ត្រី **នាល ពិសិដ្ឋ** អត្តលេខ ៥៤៤៨៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត/០២១៧/០៩០

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៧*

**លេខៈ** ០៥៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី** ០៧ **ខែ** កុម្ភៈ **ឆ្នាំ២០១៧**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣/៣

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/០៨៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោរភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **សែហេង រតនា** (SAE-HENG RATTANA) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៧៩ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

១៣៧.១៧០២.០៥១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ៧៧. ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ០៩០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **លាវ ហ៊ុយឈី** (LIU HUI-CHI) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៩ នៅខេត្តតៃវ៉ាន់ សាធារណរដ្ឋចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១៧០២.០៩២

លេខៈ ៩៦ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧*

**សំណៅចំលងមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ០៧១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **គួ ពីងសៀន** (KUO PING-HSIEN) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៣ នៅទីក្រុងតៃជុង សាធារណរដ្ឋចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.១៧០២.០៨៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ៩២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ០៩៤

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសញ្ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វ៉ាង ឌីងខាយ** (WANG DINGKAI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧២ នៅខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរម. ១៧០២.០៩៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ៥៧. ស.ណ
**សំណៅចែងមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ០៩៣

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសញ្ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់កញ្ញា **លីន ហាវ អ៊ី** (LIN HAO-YI) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨២ នៅខេត្តតៃវ៉ាន់ សាធារណរដ្ឋចិន។

**មាត្រា ២ :** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ករល. ១៧០២.០៩៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ៩០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ការគណៈ

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ៣២៣/០៦១/២០១៧
ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧
**សេចក្តីសម្រេច**
លេខ : ១៦៤/០០៤/២០១៧ កបធ.ច
ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៧

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៣៩.រស ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មជំពូកទី១២ ថ្មី ប្រការ ៤៨ ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី៣១ ខែ មករា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាវិសាមញ្ញ នីតិកាលទី៥ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧ វេលាម៉ោង ១៦:០០ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភាបានអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិនៃមាត្រា ៨២ ថ្មី វាក្យខ័ណ្ឌទី៣ មាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ និង ប្រការ ៨២ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាក្នុងការពិនិត្យនិងអនុម័តសេចក្តីស្នើវិសោធនកម្មជំពូកទី ១២ ថ្មី ប្រការ ៤៨ ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹង មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មជំពូកទី១២ ថ្មី ប្រការ ៤៨ ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជានេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តវិសោធនកម្មជំពូកទី១២ ថ្មី ប្រការ ៤៨ ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃជំពូកទី១២ ថ្មី (មួយ) ប្រការ ៤៨ ថ្មី (បួន) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ស្របនឹងរដ្ឋធម្មនុញ្ញ ។

## **សម្រេច**

**មាត្រា ១.-** វិសោធនកម្មជំពូកទី១២ ថ្មី ប្រការ ៤៨ ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាវិសាមញ្ញ នីតិកាលទី៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៧

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

**អ៊ឹម ឈុនលឹម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋសភា
-០០២.០៣៩.១៧

ក្រុមប្រឹក្សាធម្មនុញ្ញ
លេខ ១៨/២០១៧
ថ្ងៃទី ៣១.០១.១៧ ម៉ោង ១៦:០០

**សូមជម្រាបជូន**
**ឯកឧត្តម អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

សូមជ្រាប ។

**កម្មវត្ថុ: ការពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មជំពូកទី ១២ ថ្មី ប្រការ ៤៨ ថ្មី(បី) នៃបទបញ្ញាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ។**

**យោង:** -មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ
-មាត្រា ១៦ ថ្មី ផ្នែកទី ២ ជំពូកទី ២ នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
-លិខិត ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៧ របស់ឯកឧត្តមបណ្ឌិត **ម៉ែន សំអន** និង ឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប** តំណាងក្រុមតំណាងរាស្ត្រហត្ថលេខីចំនួន ៥២ រូប

ខ្ញុំ មានកិត្តិយសជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថារដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានទទួលសេចក្តីស្នើរបស់ឯកឧត្តមបណ្ឌិត **ម៉ែន សំអន** និងឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប** តំណាងក្រុមតំណាងរាស្ត្រហត្ថលេខីចំនួន ៥២ រូប សុំឲ្យរដ្ឋសភាពិនិត្យ និងអនុម័តសេចក្តីស្នើ **វិសោធនកម្មជំពូកទី ១២ ថ្មី ប្រការ ៤៨ ថ្មី(បី) នៃបទបញ្ញាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ។**

រដ្ឋសភាអនុម័តយល់ព្រមលើសេចក្តីស្នើ វិសោធនកម្ម ខាងលើដោយទទួលបានចំនួន ៦៧ សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូលនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី ៥ ។

ខ្ញុំ សូមជូនភ្ជាប់មកជាមួយនូវវិសោធនកម្មខាងលើ ជូនឯកឧត្តមប្រធានចាត់ ពិនិត្យធម្មនុញ្ញភាពជាការប្រញាប់ តាមការគួរ ។

ខ្ញុំសូម **ឯកឧត្តម** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧

ប្រធានរដ្ឋសភា

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

ចម្លងជូន:
-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
ដើម្បីជ្រាបជាព័ត៌មាន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
- លេខ : ២៧៤/០១២/២០១៧
 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៧៥/០១៣/២០១៧
 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៧៦/០១៤/២០១៧
 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧

**សេចក្ដីសម្រេច**
លេខ : ១៦៥/០០៥/២០១៧ កបធ.ច
ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៧

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្ដីសម្រេចលេខ ០២៨ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្ដីសម្រេចលេខ ០០៤ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់និរោធ ទុកជាបានការពេញទាំងមូល
- បានឃើញសេចក្ដីសម្រេចលេខ ០២៩ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្ដីសម្រេចលេខ០៣ ដល់លេខ១៣ លេខ១៩ និងលេខ ២០ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់វាលវង់ ទុកជាបានការពេញទាំងមូល

- បានឃើញសេចក្តីសម្រេចលេខ ០៣០ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្តីសម្រេចលេខ១៤ ដល់ ១៨ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់វាលវង់ ទុកជាបានការពេញទាំងមូល
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧ របស់លោក **ថ្លាង សកល** ជូន លោក **ឌិន ម៉ារិន** ក្នុងការដាក់ពាក្យប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០២៨ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧ របស់លោក **ខៀត ទីណា** ជូន លោក **ឌិន ម៉ារិន** ក្នុងការដាក់ពាក្យប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០២៩ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧ របស់លោកស្រី **ឈន គីមហៀង** ជូន លោក **ឌិន ម៉ារិន** ក្នុងការដាក់ពាក្យប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ០៣០ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតលេខ ០៨៨ គ.ជ.ប ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **មាន សទិ** និងឯកឧត្តម **សំ សារិទ្ធ** ដើម្បីមកបំភ្លឺលើ ពាក្យបណ្តឹងរបស់លោក **ឌិន ម៉ារិន**
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧ របស់លោក **ឌិន ម៉ារិន** តំណាងឲ្យ លោក **ថ្លាង សកល** លោក **ខៀត ទីណា** និងលោកស្រី **ឈន គីមហៀង** ប្តឹងជំទាស់នឹងសេចក្តី សម្រេចលេខ ០២៨ លេខ០២៩ និងលេខ០៣០ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **ឌិន ម៉ារិន** កាលពីថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៧ ចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុបំភ្លឺរបស់ឯកឧត្តម **មាន សទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៧ ដោយភ្ជាប់ សារណាចំនួន០៣ច្បាប់ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៧ និងឯកសារពាក់ព័ន្ធនឹងប្រជាពលរដ្ឋ ចំនួន ១៥៣ នាក់ ដែលត្រូវបានប្តឹងថាជាជនជាតិបរទេស
- បានឃើញកំណត់ហេតុចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៧ នៅសង្កាត់និរោធ និងសង្កាត់វាលវង់។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងទាំងបីរបស់លោក **ឌិន ម៉ារិន** ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧ ស្ថិតក្នុង ដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។ យោងតាមមាត្រា ៦២ នៃច្បាប់ស្តីពីការបោះឆ្នោត

ជ្រើសតាំងតំណាងរាស្ត្រ និងមាត្រា ២៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងនេះធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន

- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោក **ឱន ឌ៉ារិន** បានបញ្ជាក់ ដូចខាងក្រោម :

  - លោកជាតំណាងឲ្យដើមបណ្តឹង **ច្រាច សកល ខ្មៀត ទីណា** និង **ឈន គីមហៀង** ដែលប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់និរោធ និង សង្កាត់វាលវង់ និងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីធ្វើការប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ សុំលុបឈ្មោះពីបញ្ជីបោះឆ្នោតចំនួន ៣៧ នាក់ ដែលជាបណ្តឹងរបស់លោក **ច្រាច សកល** ចំនួន ៦៦ នាក់ ដែលជាបណ្តឹងរបស់លោក **ខ្មៀត ទីណា** និងចំនួន ៥០ នាក់ ដែលជាបណ្តឹងរបស់លោកស្រី **ឈន គីមហៀង** សរុបចំនួន ១៥៣ នាក់។
  - លោកបានទទួលព័ត៌មានពីតំណាង/សកម្មជនគណបក្សដែលរស់នៅជិតជនជាតិបរទេសទាំងនោះ ថាពួកគេមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរខុសច្បាប់។
  - ពួកលោកសម្គាល់ថា ជាជនជាតិបរទេសដោយសង្កេតលើសូរសៀងសំឡេងខុសពីជនជាតិខ្មែរ។ ជនជាតិបរទេសទាំងនោះនៅតែគោរពនិងប្រកាន់ប្រពៃណីរបស់ពួកគេ។
  - លោកសំណូមពរក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យភាពស្របច្បាប់នៃការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងសុំលុបឈ្មោះជនជាតិបរទេសទាំងនោះចេញពីបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៦

- យល់ឃើញថា នៅពេលបំភ្លឺចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **មាន សទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបញ្ជាក់ ដូចខាងក្រោម ៖

  - លោក **ឱន ឌ៉ារិន** ជាតំណាងឲ្យឈ្មោះ **ច្រាច សកល** ឈ្មោះ **ខ្មៀត ទីណា** និងឈ្មោះ **ឈន គីមហៀង** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០២៨ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៧ ដែលរក្សាទុកឈ្មោះប្រជាពលរដ្ឋចំនួន ៣៧ នាក់ សេចក្តីសម្រេចលេខ ០២៩ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៧ ដែលរក្សាទុកឈ្មោះប្រជាពលរដ្ឋចំនួន ៦៦ នាក់ និង សេចក្តីសម្រេចលេខ ០៣០ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរក្សាទុកឈ្មោះប្រជាពលរដ្ឋចំនួន ៥០ នាក់ ក្នុងបញ្ជីបោះឆ្នោតដំបូង ឆ្នាំ២០១៦
  - នៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លោក **ឱន ឌ៉ារិន** ប្តឹងថា ប្រជាពលរដ្ឋទាំងនោះជាជនជាតិវៀតណាម ព្រោះមានទម្រង់មុខជាជនជាតិវៀតណាម និយាយខ្មែរមិនច្បាស់ រស់នៅផ្តុំគ្នាតិច ឬក៏ច្រើន និងគោរពប្រពៃណីតាមទំនៀមទំលាប់វៀតណាម ។

- សេចក្តីសម្រេចលេខ ០២៨ លេខ ០២៩ និងលេខ ០៣០ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានតម្កល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់និរោធ និងសង្កាត់វាលវង់ ទុកជាបានការពេញទាំងមូល
- ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ០២៨ លេខ០២៩ និងលេខ០៣០ ចុះថ្ងៃទី១៩ខែមករាឆ្នាំ២០១៧ គឺផ្អែកលើមាត្រា ៥៦ និងមាត្រា ៥១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងប្រការ ៤.៤ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦
- សំណូមពរ សូមឲ្យក្រុមប្រឹក្សាធម្មនុញ្ញតម្កល់សេចក្តីសម្រេចលេខ ០២៨ លេខ ០២៩ និងលេខ ០៣០ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានជូនសារណាចំនួន ០៣ ច្បាប់ ពាក់ព័ន្ធនឹងបណ្តឹងទាំងបីនេះ។

- យល់ឃើញថា លោក **ឌិន ឆ៉ារិន** ដែលបានប្តឹងជំទាស់សេចក្តីសម្រេច លេខ ០២៨ លេខ ០២៩ និងលេខ០៣០ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងការសុំលុបឈ្មោះជនជាតិបរទេស ពុំមានឯកសារ ឬភស្តុតាង ជាលាយលក្ខណ៍អក្សរដែលអាចឲ្យក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងបីនេះបានឡើយ
- យល់ឃើញថា តាមការចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ប្រជាពលរដ្ឋដែលត្រូវលោក **ឌិន ឆ៉ារិន** ប្តឹង សុទ្ធតែបានបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតគ្រប់គ្រាន់តាមច្បាប់ បទបញ្ជា និងនីតិវិធីចុះឈ្មោះបោះឆ្នោត
- យល់ឃើញថា សេចក្តីសម្រេចលេខ០២៨ លេខ០២៩ និងលេខ០៣០ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានមូលដ្ឋានគតិយុត្តត្រឹមត្រូវ
- យល់ឃើញថា ការបញ្ជាក់អំពីជាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.** ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧ របស់លោក **ឌិន ឆ៉ារិន** តំណាងឲ្យលោក **ប្រាជ សកល** លោក **ឌៀត ទីណា** និងលោកស្រី **ឈន គីមហៀង** ភ្នាក់ងារគណបក្សសង្គ្រោះជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** តម្កល់សេចក្តីសម្រេចលេខ ០២៨ លេខ ០២៩ និងលេខ ០៣០ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាជម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

អ៊ឹម ឈុនលឹម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

- លេខ : ២៧៧/០១៥/២០១៧
  ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៧៨/០១៦/២០១៧
  ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៧៩/០១៧/២០១៧
  ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧

**សេចក្តីសម្រេច**

លេខ : ១៦៦/០០៦/២០១៧ កបធ.ច

ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៧

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០៣៥ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០៣៦ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០៣៧ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញសេចក្ដីសម្រេចលេខ ០៣៨ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្ដីសម្រេចលេខ ០៤០ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្ដីសម្រេចលេខ ០៩៥ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ របស់លោក **ជី សុខល** ផ្ទេរសិទ្ធិជូនលោក **យឹម វណ្ណា** ជាតំណាង
- បានឃើញពាក្យបណ្ដឹងចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ របស់លោក **ខឿន វីរ៉ាត់** ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០៣៥ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្ដឹងចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ របស់លោក **យឹម វណ្ណា** ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០៣៦ លេខ ០៣៧ លេខ ០៣៨ លេខ ០៤០ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្ដឹងចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ របស់លោក **សឿន វណ្ណៈ** ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០៩៥ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតលេខ ០៨៧ គ.ជ.ប ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្ដម **មាន សតិ** និង ឯកឧត្ដម **សំ សារឌុជ** ដើម្បីមកបំភ្លឺលើពាក្យបណ្ដឹងរបស់លោក **ខឿន វីរ៉ាត់** លោក **យឹម វណ្ណា** និង លោក **សឿន វណ្ណៈ**
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **ខឿន វីរ៉ាត់** កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៧ ចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **យឹម វណ្ណា** កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៧ ចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **សឿន វណ្ណៈ** កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៧ ចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុបំភ្លឺរបស់ឯកឧត្ដម **មាន សតិ** និងឯកឧត្ដម **សំ សារឌុជ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញកាលពី ថ្ងៃទី២៩

ខែមករា ឆ្នាំ២០១៧ ដោយភ្ជាប់សារណាចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៧ ចំនួន ០៣ ច្បាប់ និងឯកសារពាក់ព័ន្ធនឹងពាក្យបណ្ដឹង

- បានឃើញកំណត់ហេតុចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី២៧ និង ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៧ នៅសង្កាត់បឹងទំពន់ សង្កាត់អូរឫស្សីទី១ និងសង្កាត់ដង្កោ ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្ដឹងរបស់លោក **ខឿន ទីរ៉ាត់** លោក **យឹម វណ្ណា** និង លោក **សឿន វណ្ណៈ** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ស្ថិតក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។ យោងតាមមាត្រា ៦២នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងមាត្រា ២៦ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្ដឹងនេះធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញលោក **ខឿន ទីរ៉ាត់** ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០៣៥ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលរក្សាទុកឈ្មោះជនបរទេសចំនួន ២១ នាក់ ក្នុងបញ្ជីបោះឆ្នោតនៅសង្កាត់បឹងទំពន់ ដោយចោទថា អ្នកទាំងនេះជាជនបរទេស ព្រោះនិយាយខ្មែរមិនសូវច្បាស់ មានអ្នកខ្លះគតចេះមើលអក្សរខ្មែរ គឺមានតែឈ្មោះ **គី សម្បត្តិ** ឈ្មោះ **គឹម ម៉ុណ្ណា** និងឈ្មោះ **ឡុង វណ្ណា** ចេះមើលអក្សរខ្មែរ។ លោក **ខឿន ទីរ៉ាត់** សំណូមពរសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញស្រាវជ្រាវដល់មូលដ្ឋានរស់នៅរបស់អ្នកទាំង ២១នាក់ នោះ សុំស្រាវជ្រាវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកទាំង ២១ នាក់
- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញលោក **យឹម វណ្ណា** ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០៣៦ លេខ ០៣៧ លេខ ០៣៨ លេខ ០៤០ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរក្សាទុកឈ្មោះជនបរទេសចំនួន ៧២ នាក់ ក្នុងបញ្ជីបោះឆ្នោត នៅសង្កាត់អូរឫស្សី១ តែលោកសុំដកឈ្មោះចំនួន ២៤ នាក់ ( ស្ទួនឈ្មោះ ១ នាក់ ) ចេញពីបញ្ជីរាយនាមជនបរទេសដែលលោកបានប្ដឹងកាលនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញលោក **សឿន វណ្ណៈ** ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០៩៥ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរក្សាទុកឈ្មោះជនបរទេសចំនួន ២៨ នាក់ នៅសង្កាត់ដង្កោ ។ លោក **សឿន វណ្ណៈ** សំណូមពរសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញធ្វើការស៊ើបអង្កេតអ្នកទាំងនោះជាជនជាតិខ្មែរពិត

ប្រាកដឬទេ មានសញ្ជាតិគូបនីយកម្មដែរឬទេ បើស្រាវជ្រាវទៅឃើញថា អ្នកទាំងនោះមានលក្ខណៈស្របច្បាប់គឺរក្សាទុក បើមិនស្របច្បាប់ទេសុំលុប

- យល់ឃើញថា នៅពេលបំភ្លឺចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញឯកឧត្តម **មាន សទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបញ្ជាក់ថា ដើមបណ្តឹងទាំងបីសុំលុបឈ្មោះប្រជាពលរដ្ឋចំនួន ១២០ នាក់ ដោយសំអាងថា អ្នកទាំងនោះជាជនជាតិវៀតណាមនិយាយខ្មែរមិនច្បាស់ មិនចេះអក្សរខ្មែរ និងមានប្រពៃណីនិងទំនៀមទម្លាប់រស់នៅជាជនជាតិវៀតណាម មិនមានព្រះរាជក្រឹត្យផ្តល់សញ្ជាតិ

ក្នុងចំណោមអ្នកដែលត្រូវគេប្តឹងចំនួន ១២០ នាក់ មាន ១១៣ នាក់ ប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្នុងការចុះឈ្មោះ និង ០៧ នាក់ ប្រើឯកសារបញ្ជាក់អត្តសញ្ញាណក្នុងការចុះឈ្មោះ។

តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឯកឧត្តម **មាន សទិ** បានបញ្ជាក់ថា ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ផ្អែកលើ៖

•មាត្រា ៥១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុច ៤.៤ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦

•ការត្រួតពិនិត្យ និង ការស្រាវជ្រាវរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមរយៈឯកសាររបស់ក្រុមចុះឈ្មោះបោះឆ្នោតសង្កាត់ បញ្ជូនមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយអ្នកទាំងនោះប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្នុងការចុះឈ្មោះ និង បានចុះឈ្មោះបោះឆ្នោតនៅចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោត

•ការកំណត់សញ្ជាតិរបស់បុគ្គលម្នាក់ៗ គេអាចសម្គាល់បានតាមរយៈលិខិតយថាភូតផ្លូវការចេញដោយអាជ្ញាធរមានសមត្ថកិច្ច

•ការធ្វើការស៊ើបអង្កេតលើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរតាមរយៈការចូលសញ្ជាតិគូបនីយកម្មជាសមត្ថកិច្ចរបស់តុលាការ និងអាជ្ញាធរមានសមត្ថកិច្ច

•សំណូមពរ សូមឲ្យក្រុមប្រឹក្សាធម្មនុញ្ញតម្កល់សេចក្តីសម្រេចលេខ ០៣៥ លេខ ០៣៦ លេខ ០៣៧ លេខ ០៤០ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ ០៩៥ ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការ

- យល់ឃើញថា តាមការស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញប្រជាពលរដ្ឋដែលត្រូវដើមបណ្តឹងប្តឹងអ្នកទាំងនោះសុទ្ធតែបានបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតត្រឹមត្រូវតាមច្បាប់ បទបញ្ជា និង នីតិវិធីចុះឈ្មោះបោះឆ្នោត
- យល់ឃើញថា លោក **ខឿន ទីរ៉ាត់** លោក **យឹម ទណ្ណា** និង លោក **សឿន ទណ្ណៈ** ដើមបណ្តឹងដែលបានប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការសុំលុបឈ្មោះជនបរទេស ពុំមានឯកសារជាលាយលក្ខណ៍អក្សរ ឬភ័ស្តុតាងដែលអាចឲ្យក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឡើយ

- យល់ឃើញថា សេចក្តីសម្រេចលេខ ០៣៥ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ លេខ ០៣៦ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ លេខ ០៣៧ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ លេខ ០៣៨ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ លេខ ០៤០ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ និងលេខ ០៩៥ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានមូលដ្ឋានគតិយុត្តត្រឹមត្រូវ
- យល់ឃើញថា ការបញ្ជាក់អំពីជាតុពិតនៃអត្តញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.** ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧ របស់លោក **ខឿន ទីរ៉ាត់** លោក **យឹម វណ្ណា** និង លោក **សឿន វណ្ណៈ** ភ្នាក់ងារគណបក្សសង្គ្រោះជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** តម្កល់សេចក្តីសម្រេចលេខ ០៣៥ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ០៣៦ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ០៣៧ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ០៣៨ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ០៤០ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ ០៩៥ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៧

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

**អ៊ឹម ឈុនលឹម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
- លេខ : ២៨០/០១៨/២០១៧
  ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៨១/០១៩/២០១៧
  ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៨២/០២០/២០១៧
  ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧

**សេចក្តីសម្រេច**
លេខ : ១៦៧/០០៧/២០១៧ កបធ.ច
ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៧

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០៣២ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០៣៣ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០៣៤ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧ របស់លោក **គង់ បូរ៉ា** តំណាងគណបក្សសង្គ្រោះជាតិ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០៣២ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧ របស់លោក **សៀន រ៉ាទី** តំណាងគណបក្សសង្គ្រោះជាតិ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០៣៣ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧ របស់លោក **ហ៊ីង ហេង** តំណាងគណបក្សសង្គ្រោះជាតិ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០៣៤ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតលេខ ០៨៣ គ.ជ.ប ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **ម៉ៅ សុភារិទ្ធ** និង ឯកឧត្តម **តែ រឹទ្ធិ** ដើម្បីមកបំភ្លឺលើពាក្យបណ្តឹងរបស់លោក **គង់ ម៉ូរ៉ា** លោក **សៀន រ៉ាទី** និងលោក **ហ៊ីង ហេង**
- បានឃើញកំណត់ហេតុបំភ្លឺរបស់ឯកឧត្តម **ម៉ៅ សុភារិទ្ធ** និង ឯកឧត្តម **តែ រឹទ្ធិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៧ ភ្ជាប់ដោយសារណា ចំនួន ០៣ ច្បាប់ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៧ និងឯកសារពាក់ព័ន្ធនឹងប្រជាពលរដ្ឋចំនួន ៤១នាក់ ដែលត្រូវបានប្តឹងថាជាជនបរទេស(វៀតណាម)
- បានឃើញកំណត់ហេតុចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០១៧ នៅសង្កាត់ផ្សារថ្មីទី៣ សង្កាត់ផ្សារកណ្តាលទី១ និងសង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧ របស់លោក **គង់ ម៉ូរ៉ា** លោក **សៀន រ៉ាទី** និងលោក **ហ៊ីង ហេង** ស្ថិតក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។ យោងតាមមាត្រា ៦២ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងមាត្រា ២៦ ចំណុចទី៣ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងនេះធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា តាមពាក្យបណ្តឹងនៅក្រុមប្រឹក្សាសង្កាត់ និងការឆ្លើយបំភ្លឺនៅគ.ជ.ប លោក **គង់ ម៉ូរ៉ា** លោក **សៀន រ៉ាទី** និងលោក **ហ៊ីង ហេង** បានអះអាង និងចោទប្រកាន់ប្រហាក់ប្រហែលគ្នាថា ៖

១-ជនជាតិវៀតណាមទាំងនោះពុំមានលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ចុះឈ្មោះបោះឆ្នោត ព្រោះជាជនបរទេសគ្មានសញ្ជាតិខ្មែរ តែកាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរយកទៅចុះឈ្មោះបោះឆ្នោត។

២-ជនជាតិវៀតណាមទាំងនោះកាន់អត្តសញ្ញាណប័ណ្ណ ដោយពុំមានព្រះរាជក្រឹត្យផ្តល់សញ្ជាតិផ្ទុយនឹងមាត្រា ១៦ និង មាត្រា ១៩ នៃច្បាប់ស្តីពីសញ្ជាតិ និងខ្លះទៀតកាន់អត្តសញ្ញាណប័ណ្ណចាស់។

៣-ពួកគេជាជនជាតិវៀតណាម ដោយសារមានមុខមាត់ មានសម្លៀកបំពាក់ ការរស់នៅបែបវៀតណាម សម្តីនិយាយជាភាសាវៀតណាម និយាយខ្មែរមិនច្បាស់ មិនចេះសរសេរអក្សរខ្មែរ។

- យល់ឃើញថា នៅពេលមកដាក់ពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ លោក **គង់ ប៊ូរ៉ា** លោក **សៀន រ៉ាវី** និងលោក **ហ៊ាង ហេង** មិនមានឯកសារអ្វីបន្ថែមទៅលើពាក្យបណ្តឹងទេ ហើយដើមបណ្តឹងទាំងបីក៏មិនបានចូលមកឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញដែរ ទោះមន្ត្រីក្រុមប្រឹក្សាធម្មនុញ្ញបានប្រគល់ដីកាកោះហើយក៏ដោយ
- យល់ឃើញថា នៅពេលបំភ្លឺនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧ ឯកឧត្តម **ម៉ៅ សុភារិទ្ធ** និង ឯកឧត្តម **តែ រីទ្ធិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបំភ្លឺដូចខាងក្រោម៖

ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផ្អែកលើ ៖

១-មាត្រា ៥១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចំណុច ខ និងប្រការ ៤.៤ នៃបទបញ្ជា និង នីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ។

២-ដើមបណ្តឹងពុំមានសំអាងបញ្ជាក់ថា ក្រុមប្រឹក្សាសង្កាត់ទាំងបី មិនបានអញ្ជើញដើមបណ្តឹងចូលរួមក្នុងការសម្រេចឡើយ ។

៣-ការត្រួតពិនិត្យនិងការស្រាវជ្រាវរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមរយៈឯកសាររបស់ក្រុមចុះឈ្មោះបោះឆ្នោតសង្កាត់បញ្ជូនមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឃើញថាអ្នកចុះឈ្មោះបោះឆ្នោតដែលដើមបណ្តឹងប្តឹងមក សុទ្ធតែបានប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងបានមកចុះឈ្មោះបោះឆ្នោតនៅចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោត ។

៤-ការកំណត់សញ្ជាតិរបស់បុគ្គលម្នាក់ៗ គេអាចសម្គាល់បានតាមរយៈលិខិតយថាភូតផ្លូវការចេញដោយអាជ្ញាធរមានសមត្ថកិច្ច។ ការធ្វើការស៊ើបអង្កេតលើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរតាមរយៈការចូលសញ្ជាតូបនីយកម្ម ជាសមត្ថកិច្ចរបស់តុលាការ និងអាជ្ញាធរមានសមត្ថកិច្ច។

៥-សំណូមពរ សូមឱ្យក្រុមប្រឹក្សាធម្មនុញ្ញ តម្កល់សេចក្តីសម្រេចលេខ ០៣២ លេខ ០៣៣ និង លេខ ០៣៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការ។

- យល់ឃើញថា លោក **គង់ ប៊ូរ៉ា** លោក **សៀន រ៉ាវី** និងលោក **ហ៊ាង ហេង** ជាដើមបណ្តឹងដែលបានប្តឹងជំទាស់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការសុំលុបឈ្មោះជនបរទេស ពុំមានឯកសារ ឬ ភស្តុតាងណាមួយដែលអាចឱ្យក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងបីនេះបានឡើយ
- យល់ឃើញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រគល់ឯកសារចុះឈ្មោះអ្នកបោះឆ្នោតភ្ជាប់នឹងអត្តសញ្ញាណប័ណ្ណអ្នកបោះឆ្នោតដែលត្រូវគេប្តឹងចំនួនតែ២៥នាក់ប៉ុណ្ណោះ ក្នុងសង្កាត់ផ្សារកណ្តាលទី២ ដែលដកស្រង់ចេញពីប្រព័ន្ធកុំព្យូទ័ររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

តាមការចុះស្រាវជ្រាវរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ នៅសង្កាត់ផ្សារកណ្តាលទី២ ដោយបានផ្ទៀងផ្ទាត់បញ្ជីឈ្មោះដែលត្រូវគេប្តឹងជាមួយនឹងបញ្ជីបោះឆ្នោតដំបូងនៅសង្កាត់ផ្សារកណ្តាលទី២ ឃើញថាពុំមានឈ្មោះ **អ៊ូ ចាន់ធី** ទេ។ អ្នកស្រី **ប៉ែន អ៊ិន** ចៅសង្កាត់ផ្សារកណ្តាលទី២ ក៏បានបញ្ជាក់ថា ឈ្មោះ **អ៊ូ ចាន់ធី** ពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូងទេ ដោយឈ្មោះនេះ បានចាកចេញទៅរស់នៅសង្កាត់ឬស្សីកែវ។

- យល់ឃើញថា តាមការចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ប្រជាពលរដ្ឋដែលត្រូវលោក **គង់ មូរ៉ា** លោក **សឿន រ៉ាវី** និងលោក **ហ៊ីង ហេង** ប្ដឹង សុទ្ធតែបាន បំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតគ្រប់គ្រាន់តាមច្បាប់ បទបញ្ជា និង នីតិវិធីចុះឈ្មោះបោះឆ្នោត
- យល់ឃើញថា សេចក្ដីសម្រេចលេខ០៣២ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ លេខ០៣៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ និង លេខ០៣៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានមូលដ្ឋានគតិយុត្តត្រឹមត្រូវ តែក្នុងសេចក្ដីសម្រេចលេខ០៣៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ គប្បីបដិសេធចោលការរក្សាឈ្មោះ **អ៊ូ ចាន់ធី** ដែលពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូងនៃសង្កាត់ផ្សារកណ្ដាលទី២
- យល់ឃើញថា ការបញ្ជាក់អំពីធាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

# សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៧ របស់លោក **គង់ មូរ៉ា** លោក **សឿន រ៉ាវី** លោក **ហ៊ីង ហេង** តំណាងគណបក្សសង្គ្រោះជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

**មាត្រា ២.-** តម្កល់សេចក្ដីសម្រេចលេខ ០៣២ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ ០៣៣ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល។

**មាត្រា ៣.-** តម្កល់សេចក្ដីសម្រេចលេខ ០៣៤ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការ តែបដិសេធចោលការរក្សាឈ្មោះ **អ៊ូ ចាន់ធី** ដែលពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូងនៃសង្កាត់ផ្សារកណ្ដាលទី២។

**មាត្រា ៤.-** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៧ នាកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៧

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

**អ៊ុម ឈុនលីម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ២៨៣/០២១/២០១៧
ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧

**សេចក្តីសម្រេច**
លេខ : ១៦៨/០០៨/២០១៧ កបធ.ច
ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០៩២ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ របស់លោក **សែម សុផាត** ផ្ទេរសិទ្ធិជូនលោកមេធាវី **ចាន់ ចេន** ជាតំណាង
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ របស់លោកមេធាវី **ចាន់ ចេន** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០៩២ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញលិខិតលេខ ០៩៤ គ.ជ.ប ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **តែ រិទ្ធិ** និងលោក **ហួត បូរិន** ដើម្បីមកបំភ្លឺលើពាក្យបណ្ដឹងរបស់លោកមេធាវី **ចាន់ ចេន** តំណាងឱ្យលោក **សែម សុផាត**
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោកមេធាវី **ចាន់ ចេន** កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុបំភ្លឺរបស់ឯកឧត្តម **តែ រិទ្ធិ** និងលោក **ហួត បូរិន** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញកាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ដោយភ្ជាប់សារណាចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ចំនួន ០១ ច្បាប់ និងឯកសារពាក់ព័ន្ធនឹងពាក្យបណ្ដឹង
- បានឃើញកំណត់ហេតុចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៧ នៅឃុំកំពង់ប្រាសាទ ស្រុកពាមជរ ខេត្តព្រៃវែង។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្ដឹងរបស់លោកមេធាវី **ចាន់ ចេន** តំណាងឱ្យលោក **សែម សុផាត** ភ្នាក់ងារគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ ស្ថិតក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។ យោងតាមមាត្រា ៦២ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងមាត្រា ២៦ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្ដឹងនេះធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញលោកមេធាវី **ចាន់ ចេន** ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០៩២ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលរក្សាទុកឈ្មោះជនបរទេសចំនួន ០៩ នាក់ ក្នុងបញ្ជីបោះឆ្នោតនៅឃុំកំពង់ប្រាសាទថា ខ្ញុំស្គាល់អ្នកទាំង ០៩ នាក់ តាមរយៈលិខិតផ្ទេរសិទ្ធិពីលោក **សែម សុផាត** តែប៉ុណ្ណោះ ហើយខ្ញុំប្ដឹងពួកគាត់ដោយសារតែពួកគាត់និយាយភាសាខ្មែរមិនច្បាស់ ហើយពួកគាត់មួយចំនួនមានឪពុកម្ដាយជាជនជាតិវៀតណាម មានវប្បធម៌ ការនិយាយស្ដី ការស្លៀកពាក់ និងការប្រារព្ធពិធីជាលក្ខណៈវៀតណាម។ ខ្ញុំមិនដឹងថាពួកគាត់យកឯកសារអ្វីទៅចុះឈ្មោះបោះឆ្នោតនោះទេ ព្រោះដើម្បីបានសញ្ជាតិខ្មែរ គឺទាល់តែពួកគាត់មានព្រះរាជក្រឹត្យទទួលស្គាល់
- យល់ឃើញថា នៅពេលបំភ្លឺចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **តែ រិទ្ធិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបញ្ជាក់ថា ដើមបណ្ដឹងប្ដឹងសុំលុបឈ្មោះអ្នកចុះឈ្មោះ

បោះឆ្នោតទាំង ០៩ នាក់នោះ ដោយសំអាងថា អ្នកចុះឈ្មោះទាំងនោះគ្មានឯកសារបញ្ជាក់ច្បាស់លាស់អំពីសញ្ជាតិ ដូចជា ព្រះរាជក្រឹត្យ ឬសាលក្រមរបស់តុលាការជាដើម

ក្នុងចំណោមអ្នកដែលត្រូវគេប្តឹងចំនួន ០៩ នាក់ មាន ០៣ នាក់ ប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្នុងការចុះឈ្មោះ និង ០៦ នាក់ទៀត ប្រើឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតដោយភ្ជាប់ជាមួយសៀវភៅគ្រួសារ និងសំបុត្រកំណើតក្នុងការចុះឈ្មោះបោះឆ្នោត។

តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឯកឧត្តម **តែ រិទ្ធិ** បានបញ្ជាក់ថា ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ផ្អែកលើ ៖

•មាត្រា ៤៦ មាត្រា ៥១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុច ៤.៤ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦

•ការត្រួតពិនិត្យ និង ការស្រាវជ្រាវរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ធ្វើតាមរយៈឯកសាររបស់ក្រុមចុះឈ្មោះបោះឆ្នោតឃុំកំពង់ប្រាសាទ ដែលបញ្ជូនមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

•ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ឃើញថា សេចក្តីសម្រេចលេខ ០០១ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃឃុំកំពង់ប្រាសាទ មានលក្ខណៈមិនត្រឹមត្រូវ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណាបដិសេធចោល។ ដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានសម្រេចបដិសេធសេចក្តីសម្រេចលេខ ០០១ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាឃុំកំពង់ប្រាសាទចោលជាអសារបង់ និងរក្សាទុកឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតទាំង ០៩ នាក់ ក្នុងបញ្ជីបោះឆ្នោតដំបូងឃុំកំពង់ប្រាសាទដដែល ។ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសំណូមពរមកក្រុមប្រឹក្សាធម្មនុញ្ញ សុំតម្កល់សេចក្តីសម្រេចលេខ ០៩២ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការ

- យល់ឃើញថា តាមការស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ប្រជាពលរដ្ឋដែលត្រូវដើមបណ្តឹងប្តឹង អ្នកទាំងនោះសុទ្ធតែបានបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតត្រឹមត្រូវតាមច្បាប់ បទបញ្ជា និង នីតិវិធីចុះឈ្មោះបោះឆ្នោត
- យល់ឃើញថា លោកមេធាវី **ចាន់ ចេន** តំណាងឱ្យលោក **សែម សុផាត** ដែលបានប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការសុំលុបឈ្មោះជនបរទេស ពុំមានឯកសារជាលាយលក្ខណ៍អក្សរ ឬភស្តុតាងដែលអាចឲ្យក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឡើយ
- យល់ឃើញថា សេចក្តីសម្រេចលេខ ០៩២ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានមូលដ្ឋានគតិយុត្តត្រឹមត្រូវ

- យល់ឃើញថា ការបញ្ជាក់អំពីធាតុពិតនៃអត្តញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧ របស់លោកមេធាវី **ចាន់ ចេន** តំណាងឱ្យលោក **សែម សុផាត** ភ្នាក់ងារគណបក្សសង្គ្រោះជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្ដីសម្រេចលេខ ០៩២ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

**អ៊ឹម ឈុនលឹម**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងនិងការកំណត់បៀវត្សប្រចាំខែនិងការឧបត្ថម្ភផ្សេងៗ សម្រាប់មន្ត្រីរាជការនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០២/០០១ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការការបរទេស

- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- បានឃើញអនុក្រឹត្យលេខ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងរៀបចំការគ្រប់គ្រងនិងការកំណត់បៀវត្សប្រចាំខែនិងការឧបត្ថម្ភផ្សេងៗសម្រាប់មន្ត្រីរាជការនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់៖

- បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ
- ការគ្រប់គ្រងមន្ត្រីនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស
- វិធាននៃការបើកផ្តល់បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិកម្ពុជា និងបុគ្គលិកដែលត្រូវបានចាត់តាំងឱ្យទៅបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស។

## ជំពូកទី២
## ការកំណត់បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ

**មាត្រា៤.-**

បៀវត្សប្រចាំខែនិងប្រាក់ឧបត្ថម្ភឈ្នួលផ្ទះរបស់មន្ត្រីរាជការស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិកម្ពុជា និងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេសត្រូវបានកំណត់ទៅតាមប្រភេទចំណាត់ថ្នាក់ប្រទេសដូចខាងក្រោម៖

| លរ | ប្រភេទប្រទេស "ក" | ប្រភេទប្រទេស "ខ" | ប្រភេទប្រទេស "គ" |
|---|---|---|---|
| ១ | ប្រទេសអូស្ត្រាលីនិងនូវែលសេឡង់<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅកង់បេរ៉ា | ប្រទេសព្រុយណេដារូសាឡាម<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅបានដាសេរីបេហ្គាវ៉ាន់ | សាធារណរដ្ឋប៊ុលហ្គារី<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅសូហ្វីយ៉ា |

| ល.រ | ប្រភេទប្រទេស "ក" | ប្រភេទប្រទេស "ខ" | ប្រភេទប្រទេស "គ" |
|---|---|---|---|
| ២ | ប្រទេសបែលហ្ស៊ិក<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅព្រុចសែល<br>-ស្ថានបេសកកម្មអចិន្ត្រៃយ៍អមសហគមន៍អឺរ៉ុប-ព្រុចសែល | សាធារណរដ្ឋគុយបា<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅឡាហាវ៉ាន | សាធារណរដ្ឋឆែក<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅប្រាក |
| ៣ | ប្រទេសកាណាដា<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅអូតាវ៉ា | | សាធារណរដ្ឋហុងគ្រី<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅប៊ុយដាប៉ែស |
| ៤ | សាធារណរដ្ឋប្រជាមានិតចិន<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅប៉េកាំង | - ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងហុងកុងនិងម៉ាកាវ<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងសៀងហៃ<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងឆុងឈីង<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងគុនមិញ<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងណាននីង<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងស៊ីអាន<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងក្វាងចូវ | |
| ៥ | សាធារណរដ្ឋបារាំង<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅប៉ារីស<br>- ស្ថានគណៈប្រតិភូអចិន្ត្រៃយ៍ប្រចាំនៅអង្គការយូណេស្កូ | សាធារណរដ្ឋឥណ្ឌា<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅញូដេលី | |
| ៦ | សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅប៊ែរឡាំង | សាធារណរដ្ឋឥណ្ឌូណេស៊ី<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅហ្សាការតា<br>-ស្ថានតំណាងអចិន្ត្រៃយ៍អមលេខាធិការដ្ឋានអាស៊ាន | |
| ៧ | ប្រទេសជប៉ុន<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅតូក្យូ | សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅព្យុងយ៉ាង | |
| ៨ | សាធារណរដ្ឋកូរ៉េខាងត្បូង<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅសេអ៊ូល | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅវៀងចន្ទន៍<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងប៉ាក់សេ | |

| ល.រ | ប្រភេទប្រទេស "ក" | ប្រភេទប្រទេស "ខ" | ប្រភេទប្រទេស "គ" |
|---|---|---|---|
| ៩ | រដ្ឋកូវ៉ែត<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅកូវ៉ែត | ប្រទេសម៉ាឡេស៊ី<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅគូឡាឡាំពួ | |
| ១០ | សហព័ន្ធរុស្ស៊ី<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅមូស្គូ | ប្រទេសមីយ៉ាន់ម៉ា<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅយ៉ាងហ្គូន | |
| ១១ | ប្រទេសស្វ៊ីស<br>- ស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំអង្គការសហប្រជាជាតិ អង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិនានានៅហ្សឺណែវ | សាធារណរដ្ឋហ្វីលីពីន<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅម៉ានីល | |
| ១២ | ចក្រភពអង់គ្លេស<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅទីក្រុងឡុងដ៍ | ប្រទេសសេណេហ្គាល់<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅដាកា | |
| ១៣ | សហរដ្ឋអាមេរិក<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅវ៉ាស៊ីនតោន<br>- ស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំអង្គការសហប្រជាជាតិនៅញូវយ៉ក | សាធារណរដ្ឋសិង្ហបុរី<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅសិង្ហបុរី | |
| ១៤ | សាធារណរដ្ឋអារ៉ាប់អេហ្ស៊ីប<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅទីក្រុងគែរ | ព្រះរាជាណាចក្រថៃ<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅបាងកក<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅខេត្តសាកែវ | |
| ១៥ | | សាធារណរដ្ឋសង្គមនិយមវៀតណាម<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅហាណូយ<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងហូជីមិញ | |

**មាត្រា៥ .-**

បៀវត្សប្រចាំខែរបស់មន្ត្រីនិងបុគ្គលិកដែលបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស ត្រូវបានកំណត់ដូចខាងក្រោម៖

ឯកតា៖ គិតជាដុល្លារអាមេរិក

| ល.រ | មុខតំណែង | ប្រភេទប្រទេស | | |
|---|---|---|---|---|
| | | ក | ខ | គ |
| ១ | - ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព | ៣ ២០០ | ២ ៦០០ | ២ ៥០០ |

| ល.រ | មុខតំណែង | ប្រភេទប្រទេស | | |
|---|---|---|---|---|
| | | ក | ខ | គ |
| ២ | - អនុប្រធានស្ថានតំណាងអចិន្ត្រៃយ៍(ឋានៈជាអគ្គរាជទូត) | ៣ ០០០ | | |
| ៣ | - ភារធារីពេញសមត្ថភាព<br>- អគ្គទីប្រឹក្សាស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍ | ២ ៧០០ | ២ ២០០ | ២ ១០០ |
| ៤ | - ទីប្រឹក្សាស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍<br>- ទីប្រឹក្សាយោធា<br>- ទីប្រឹក្សានគរបាលជាតិ<br>- ទីប្រឹក្សាបច្ចេកទេស(សេដ្ឋកិច្ច ពាណិជ្ជកម្ម អប់រំ វប្បធម៌ និងការងារពលករ)<br>- អគ្គកុងស៊ុល | ២ ៤០០ | ២ ០០០ | ១ ៩០០ |
| ៥ | - លេខាធិការទី១ ស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍<br>- អនុព័ន្ធយោធា<br>- អនុព័ន្ធនគរបាលជាតិ<br>- អនុព័ន្ធជំនាញបច្ចេកទេស(សេដ្ឋកិច្ច ពាណិជ្ជកម្ម អប់រំ វប្បធម៌ និងការងារពលករ) | ២ ៣០០ | ១ ៨០០ | ១ ៧០០ |
| ៦ | - លេខាធិការទី២ ស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍<br>- កុងស៊ុល<br>- អនុព័ន្ធយោធារង | ២ ១០០ | ១ ៦០០ | ១ ៥០០ |
| ៧ | - លេខាធិការទី៣ ស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍<br>- អនុកុងស៊ុល | ២ ០០០ | ១ ៥០០ | ១ ៤០០ |
| ៨ | - អនុព័ន្ធស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍<br>- អនុព័ន្ធទទួលបន្ទុកគណនេយ្យ<br>- ភ្នាក់ងារកុងស៊ុលទទួលបន្ទុកគណនេយ្យ | ១ ៩០០ | ១ ៤០០ | ១ ៣០០ |
| ៩ | - គណនេយ្យករ<br>- បុគ្គលិករដ្ឋបាលនិងបច្ចេកទេស (ជំនួយការរដ្ឋបាល យោធា ជំនួយការទីប្រឹក្សាការងារ) | ១ ៦០០ | ១ ៣០០ | ១ ២០០ |
| ១០ | - បុគ្គលិកសេវា(អ្នកបើកបរនិងអ្នកដាំស្ល) | ១ ៤០០ | ១ ១០០ | ១ ០០០ |

**មាត្រា៦ ..**

បុគ្គលិកសេវាពុំទទួលបានប្រាក់ឧបត្ថម្ភឈ្នួលផ្ទះឡើយ។ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ត្រូវបានផ្តល់ជូនមន្ត្រី និងបុគ្គលិករដ្ឋបាលនិងបច្ចេកទេសដែលមិនមានអគារស្នាក់នៅផ្អែកលើការកំណត់ដូចខាងក្រោម៖

ឯកតា៖ គិតជាដុល្លារអាម៉េរិក

| ល.រ | មុខតំណែង | ប្រភេទប្រទេស | | |
|---|---|---|---|---|
| | | ក | ខ | គ |
| ១ | ចាប់ពីថ្នាក់អនុប្រធានស្ថានតំណាងអចិន្ត្រៃយ៍ដល់ថ្នាក់លេខាធិការទី១និងថ្នាក់ប្រហាក់ប្រហែល(យោងតាមតារាងដែលមានកំណត់ក្នុងមាត្រា៥ខាងលើ) | ១ ៥០០ | ១ ២០០ | ១ ១០០ |

| ល.រ | មុខតំណែង | ប្រភេទប្រទេស | | |
|---|---|---|---|---|
| | | ក | ខ | គ |
| ២ | ចាប់ពីថ្នាក់លេខាធិការទី២ដល់ថ្នាក់អនុព័ន្ធស្ថានទូតនិងថ្នាក់ប្រហាក់ប្រហែល(យោងតាមតារាងដែលមានកំណត់ក្នុងមាត្រា៥ខាងលើ) | ១ ៤០០ | ១ ១០០ | ១ ០០០ |
| ៣ | បុគ្គលិករដ្ឋបាលនិងបច្ចេកទេស និងថ្នាក់ប្រហាក់ប្រហែល (យោងតាមតារាងដែលមានកំណត់ក្នុងមាត្រា៥ខាងលើ) | ១ ៣០០ | ១ ០០០ | ៩០០ |

**មាត្រា៧ .-**

ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូនប្រចាំខែរបស់មន្ត្រី និង បុគ្គលិកដែលបំពេញមុខងារដូចមានក្នុងតារាងនៃមាត្រា៥ខាងលើ លើកលែងតែបុគ្គលិកសេវា ត្រូវបានកំណត់ដូចតទៅ៖

- ប្រពន្ធឬប្ដីត្រូវទទួលប្រាក់ឧបត្ថម្ភសហព័ទ្ធប្រចាំខែចំនួន២០០(ពីររយ)ដុល្លារអាម៉េរិកសម្រាប់សហព័ទ្ធដែលទៅតាមនិងត្រូវមានសំបុត្រអាពាហ៍ពិពាហ៍បញ្ជាក់
- កូនក្នុងបន្ទុកដែលមានអាយុក្រោម១៨ឆ្នាំ ត្រូវទទួលប្រាក់ឧបត្ថម្ភប្រចាំខែចំនួន១០០(មួយរយ)ដុល្លារអាម៉េរិកសម្រាប់កូនដែលទៅតាមឪពុកឬម្ដាយនិងត្រូវមានសំបុត្រកំណើតបញ្ជាក់។

**មាត្រា៨ .-**

ឯកអគ្គរាជទូត ត្រូវបានអនុញ្ញាតឱ្យយកប្រពន្ធឬប្ដី ព្រមទាំងកូនក្នុងបន្ទុកដែលមានអាយុក្រោម១៨ឆ្នាំទៅតាមដោយរដ្ឋជួយឧបត្ថម្ភរ៉ាប់រងសំបុត្រយន្តហោះថ្នាក់ជំនួញ(Business Class)សម្រាប់ពេលធ្វើដំណើរទៅកាន់តំណែងដំបូងនៅបរទេសនិងសំបុត្រយន្តហោះថ្នាក់ធម្មតា(Economy Class)ពេលចប់អាណត្តិវិលត្រឡប់មកប្រទេសវិញ។

មន្ត្រីនិងបុគ្គលិកថ្នាក់ផ្សេងទៀតដូចមានក្នុងមាត្រា៥នៃអនុក្រឹត្យនេះត្រូវទទួលបានការរ៉ាប់រងសំបុត្រយន្តហោះថ្នាក់ធម្មតា(Economy Class)ពីរដ្ឋដើម្បីធ្វើដំណើរទៅកាន់តំណែងដំបូងនៅបរទេសនិងវិលត្រឡប់មកប្រទេសវិញពេលចប់អាណត្តិ។

**មាត្រា៩ .-**

ឯកអគ្គរាជទូត ត្រូវបានផ្ដល់ប្រាក់ឧបត្ថម្ភសម្រាប់រ៉ាប់រងថ្លៃដឹកឥវ៉ាន់ដែលលើសទម្ងន់ចំនួនសរុបមិនលើសពី ៧០(ចិតសិប)គីឡូក្រាមសម្រាប់ការធ្វើដំណើរដូចមានចែងក្នុងមាត្រា៨ខាងលើនេះ។

មន្ត្រីនិងបុគ្គលិកថ្នាក់ផ្សេងទៀត ត្រូវបានផ្ដល់ប្រាក់ឧបត្ថម្ភសម្រាប់រ៉ាប់រងថ្លៃដឹកឥវ៉ាន់ដែលលើសទម្ងន់ចំនួនសរុបមិនលើសពី៥០(ហាសិប)គីឡូក្រាមសម្រាប់ការធ្វើដំណើរដូចមានចែងក្នុងមាត្រា៨ខាងលើនេះ។

**មាត្រា១០ .-**

ការកែប្រែចំណាត់ថ្នាក់ប្រទេស ការបង្កើត ការលុប និងការកែសម្រួលមុខតំណែងមន្ត្រីនិងបុគ្គលិកនៅតាមស្ថានតំណាងកម្ពុជានៅបរទេស ព្រមទាំងការកែសម្រួលបៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣
## ការគ្រប់គ្រងមន្ត្រីនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស

**មាត្រា១១ .-**

ការពិពណ៌នាមុខតំណែងមន្ត្រី និង បុគ្គលិកទាំងអស់ដែលបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេសត្រូវកំណត់ដោយប្រកាសដោយឡែករបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា១២ .-**

មុខតំណែងដែលត្រូវបានតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យរួមមានៈ

- ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព
- អនុប្រធានស្ថានតំណាងអចិន្ត្រៃយ៍(ឋានៈជាអគ្គរាជទូត)។

មុខតំណែងដែលត្រូវបានតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអនុក្រឹត្យ រួមមានៈ

- ភារធារីពេញសមត្ថភាព
- អគ្គទីប្រឹក្សាស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍
- ទីប្រឹក្សាស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍
- ទីប្រឹក្សាយោធា
- ទីប្រឹក្សានគរបាលជាតិ
- ទីប្រឹក្សាបច្ចេកទេស(សេដ្ឋកិច្ច ពាណិជ្ជកម្ម អប់រំ វប្បធម៌ និងការងារពលករ)
- អគ្គកុងស៊ុល។

ក្រៅពីមុខតំណែងខាងលើ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីនិងបុគ្គលិកដែលមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះ ត្រូវសម្រេចដោយប្រកាសរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីនិងបុគ្គលិកពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវសម្រេចឬលើកសំណើដោយរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិជូននាយករដ្ឋមន្ត្រី។

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីនិងបុគ្គលិកពីក្រសួង ស្ថាប័នផ្សេង ត្រូវផ្អែកលើសំណើរបស់ប្រធានស្ថាប័នពាក់ព័ន្ធមកក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីចេញប្រកាសឬលើកសំណើជូននាយករដ្ឋមន្ត្រី។

មន្ត្រីនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស មានអាណត្តិ៣(បី)ឆ្នាំ។

## ជំពូកទី៤
## វិធាននៃការបើកផ្តល់បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ

**មាត្រា១៣ .-**

ការបើកផ្តល់បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ ដែលមានចែងក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះ ត្រូវអនុវត្តដោយធ្វើការផ្ទេរតាមធនាគារជាតិនៃកម្ពុជា នៅរៀងរាល់ត្រីមាសនីមួយៗ។

**មាត្រា១៤ .-**

ថវិកាសម្រាប់បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗរបស់មន្ត្រីនិងបុគ្គលិកបំពេញភារកិច្ចនៅបរទេស ត្រូវគ្រោងក្នុងកញ្ចប់ថវិការបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា១៥ .-**

ឯកអគ្គរាជទូត អគ្គកុងស៊ុល ឬប្រធានស្ថានតំណាងអចិន្ត្រៃយ៍ ត្រូវទទួលបៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ និងប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូនចាប់តាំងពីថ្ងៃដែលទទួលបានការយល់ព្រម(Agrément)ពីរដ្ឋាភិបាលម្ចាស់ផ្ទះ ដោយថតចម្លងនូវលិខិតឆ្លងដែន សំបុត្រយន្តហោះ កិច្ចសន្យាជួលផ្ទះ សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រកំណើតបញ្ជូនមកក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

មន្ត្រីនិងបុគ្គលិកថ្នាក់ផ្សេងទៀតនៅស្ថានតំណាង នឹងទទួលបានបៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ និងប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន ក្រោយរយៈពេល១(មួយ)ខែនៃកាលបរិច្ឆេទតែងតាំងជាផ្លូវការនិងត្រូវថតចម្លងនូវលិខិតឆ្លងដែន សំបុត្រយន្តហោះ កិច្ចសន្យាជួលផ្ទះ សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រកំណើតបញ្ជូនមកក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

មន្ត្រីនិងបុគ្គលិកដែលត្រូវបានតែងតាំងឱ្យទៅបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស ត្រូវទទួលបៀវត្សនិងការឧបត្ថម្ភផ្សេងៗអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះនិងមិនត្រូវទទួលបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ ព្រមទាំងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីសាធារណៈនៅក្នុងប្រទេសឡើយ។

**មាត្រា១៦ .-**

មន្ត្រីនិងបុគ្គលិកដែលបញ្ចប់ភារកិច្ចពីស្ថានតំណាងកម្ពុជានៅបរទេសត្រូវទទួលបៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ ១(មួយ)ខែ បន្ទាប់ពីថ្ងៃបញ្ចប់អាណត្តិបេសកកម្មអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ដើម្បីរៀបចំឯកសារនិងផ្ទេរការងារផ្សេងៗនិងត្រូវមកបង្ហាញខ្លួននៅអង្គភាពដើមយ៉ាងយូរក្នុងសប្តាហ៍ទី២ ក្រោយពីការបញ្ចប់ភារកិច្ចវិលចូលប្រទេសវិញ។

មន្ត្រីនិងបុគ្គលិកដែលបញ្ចប់ភារកិច្ចពីស្ថានតំណាងកម្ពុជានៅបរទេស ត្រូវទទួលបានការរៀបចំផ្តល់បៀវត្សមូលដ្ឋានស្របតាមក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់សាមីខ្លួន ព្រមទាំងប្រាក់បំណាច់មុខងារផ្អែកលើមុខតំណែងក្នុងមុខងារសាធារណៈដែលមានមុនពេលតែងតាំងឱ្យទៅបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេសនិងប្រាក់បន្ទាប់បន្សំផ្សេងទៀតអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មន្ត្រីនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេសត្រូវបានដំឡើងថ្នាក់និង/ឬឋានន្តរស័ក្តិដោយស្វ័យប្រវត្តិ នៅថ្ងៃទី១៣ ខែមេសានៃឆ្នាំនីមួយៗផ្អែកលើអតីតភាពការងារ ២(ពីរ)ឆ្នាំ។

មន្ត្រីនិងបុគ្គលិកនឹងទទួលបានសិទ្ធិអាទិភាពក្នុងការតែងតាំងក្នុងមុខតំណែងទំនេរសមស្របផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ននិងការសម្រេចរបស់ប្រធានស្ថាប័ន។

**មាត្រា១៧ .-**

បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ តទៅ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៨ .-**

អនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ស្តីពីប្រាក់បំណាច់និងប្រាក់ឧបត្ថម្ភផ្សេងៗសំរាប់មន្ត្រីរាជការបំពេញភារកិច្ចនៅក្រៅប្រទេស និង អនុក្រឹត្យលេខ៤៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០២ ស្តីពីការដំឡើងប្រព័ន្ធហិរញ្ញកិច្ចសម្រាប់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋគុយបា និងស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំក្រុងហូជីមិញនិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

| | | |
|---|---|---|
| **ទេសរដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី** | |
| **រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ** | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** |
| **ប្រាក់ សុខុន** | **អូន ព័ន្ធមុនីរ័ត្ន** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១៦ ៤៩១ ៦០០ ០០០ រៀល (ដប់ប្រាំមួយប៊ីលានបួនរយកៅសិបមួយលានប្រាំមួយរយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ប្រាក់កម្រៃសម្រាប់ត្រីមាសទី ២ និងត្រីមាសទី ៣ ឆ្នាំ ២០១៦ ទៅឱ្យក្រុមហ៊ុន ដាតា មេនេចមេន សេនធ័រ (DMC)។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨៤ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការតម្លើងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** តម្លើងថ្នាក់តាមកម្រិតសញ្ញាបត្រ ដល់លោក **អ៊ុំ ម៉ន** ពីឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៣ មកឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ២ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងយុត្តិធម៌។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៥. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា ១.-** តែងតាំងមន្ត្រីរាជការចំនួន ០២រូប ជាទីប្រឹក្សាអមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖

១-លោក **អាំង សេងលី** ជាទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយករង**

២-លោក **លាង វិសាល** ជាទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយករង**។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៧៦...អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
-បានឃើញអនុក្រឹត្យ លេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិថ្នាក់វរសេនីយ៍ឯក ជូនលោកវរសេនីយ៍ទោ **ពេញ ម៉េហុង** អត្តលេខ ០៧១៨៧ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេច នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ...៩៧...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាអធិការ នៃអគ្គាធិការដ្ឋាន នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដូចមានរាយនាមខាងក្រោម៖

១- លោក **ញូង ពៅ** ជាអធិការ នៃអគ្គាធិការដ្ឋាន ជំនួសលោក **ព្រហ្ម ដួលីន** ដែលបានទទួលភារកិច្ចថ្មី
២- លោក **ម៉ុក ភិត្យា** ជាអធិការ នៃអគ្គាធិការដ្ឋាន ជំនួសលោក **សៀង ពុទ្ធា** ដែលបានទទួលភារកិច្ចថ្មី។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងក្រសួងឧស្សាហកម្ម និងសិប្បកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ដាក់លោកស្រី **សេខ ឫទី** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៤ អតីតប្រធាននាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស បន្តលើកទី២ រយៈពេល ០១ឆ្នាំ ចាប់ពីថ្ងៃទី ០១ខែ មករា ឆ្នាំ ២០១៧ ដល់ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០១៧។

**មាត្រា ២ .-** មន្ត្រីរាជការខាងលើ ត្រូវដាក់ពាក្យសុំចូលបម្រើការងារវិញ រយៈពេល ០២ ខែ មុនពេលកំណត់។ ក្នុងករណីសាមីខ្លួនមិនដាក់ពាក្យទេ ចាត់ទុកថាបោះបង់ការងារ និងត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌជាស្ថាពរ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០២/០០១ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តាំងស៊ប់ក្នុងក្របខ័ណ្ឌដល់មន្ត្រីរាជការ ចំនួន ០៤ រូប ទៅក្នុងឋានន្តរស័ក្តិក្រមការការបរទេស នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចាប់ពីថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៦ តទៅ ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១- លោក **ហួត វិជ្ជា** | ក្រមការការបរទេស | ថ្នាក់លេខ ៤ |
| ២- លោកស្រី **ហោ ដូល្លា** | ក្រមការការបរទេស | ថ្នាក់លេខ ៤ |
| ៣- លោកស្រី **នាក់ ដាលីន** | ក្រមការការបរទេស | ថ្នាក់លេខ ៤ |
| ៤- លោកស្រី **ស្រេង ធីតា** | ក្រមការការបរទេស | ថ្នាក់លេខ ៤ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់ តាមកម្រិតសញ្ញាបត្រ ដល់មន្ត្រីរាជការចំនួន ០៥ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១- លោក **ទេព ពុទ្ធា** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២- លោក **ស៊ា គីមសៃ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៣- លោក **ផុន ផលពិសិដ្ឋ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤- លោកស្រី **សំ ខាន់ដា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៥- លោក **ឈុន ឌុធ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងជំនួយការរដ្ឋមន្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **សន ច័ន្ទរិទ្ធី** ជាជំនួយការរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើ អគ្គនាយករង។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- វរសេនីយ៍ទោ **រស់ សារុំ** អត្តលេខ ០១៨៦៤

២- វរសេនីយ៍ទោ **ហាក្យ ម៉ិនរឿន** អត្តលេខ ០៤៩៦៤

៣- វរសេនីយ៍ទោ **ឡុក ចន្ថា** អត្តលេខ ០៧៥៩៣

៤- វរសេនីយ៍ទោ **រៀល សុភា** អត្តលេខ ៥៦០៦៦

៥- វរសេនីយ៍ទោ **ហួម តាំងហឿត** អត្តលេខ ៥៦៦១៤

៦- វរសេនីយ៍ទោ **ឈួ ចាន់ថន** អត្តលេខ ៥៧៩០៦

៧- វរសេនីយ៍ទោ **នួន ឧុទ្ធិន** អត្តលេខ ៦១៩២៧

៨- វរសេនីយ៍ទោ **ហាង សម្បត្តិ** អត្តលេខ ៦៣៣៧២

៩- វរសេនីយ៍ទោ **ហ៊ុយ ច័ន្ទពិសិដ្ឋ** អត្តលេខ ៦៦០០៩

១០- វរសេនីយ៍ទោ **ឡាយ ម៉េងហួ** អត្តលេខ ៦៧៥៩១ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

**នាយករដ្ឋមន្ត្រី**



**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងកាប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១ :** តែងតាំងមន្ត្រីគ្រប់គ្រងចំនួន ០២ រូប នៃសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ របស់ក្រសួងអប់រំ យុវជន និងកីឡា៖

១- លោក **ស៊ាន សុព័ន** ជាព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម

២- លោក **អៀង លីណា** ជាព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រ និងគណិតសាស្ត្រ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **សុខ ច្រាំង** អត្តលេខ ៣២១១៨ នាយនគរបាលជាន់ខ្ពស់ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ..៩១៥..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** -.ប្រគេន និងបំពាក់មេដាយជូនព្រះតេជគុណ និងសប្បុរសជន ដែលមានស្នាដៃក្នុងការកសាងផ្លូវដីក្រហម០១ខ្សែ អាគារសិក្សាចំនួន០៦ខ្នង និងបង្គន់ចំនួន០២ខ្នង ក្នុងឃុំព្រៃតូច ស្រុកមោងឬស្សី ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមៈ

**ក- មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ធិបឌិន្ទៈ**

១- ព្រះតេជគុណ **ខ សុខជ្ញា** ក្រុមការងារអនុវត្តគម្រោងអង្គការ CAMBODIAN VILLAGE FUND នៅកម្ពុជា
២- លោក **វល្លៀម ចេ ប្លាមបឺហ្គឺ** (Mr.WILLIAM J.BAMBERGER)សហនាយកអង្គការ CAMBODIAN VILLAGE FUND
៣- លោកស្រី **ណាន់ស៊ី ចេ ប្លាមបឺហ្គឺ** (Mrs.NANCY J.BAMBERGER)សហនាយកអង្គការ CAMBODIAN VILLAGE FUND

**ខ- មេដាយមុនីសារាភ័ណ្ឌ ថ្នាក់សេនាៈ**

១- ឧបាសិកា **ម៉ន សឿន** សប្បុរជន
២- លោក **ណេល ផេតថែល** (Mr.NEIL PATEL) សប្បុរជន
៣- លោក **ធីម៉ូស៊ី សាយក៍** (Mr.TIMOTHY SYKES) សប្បុរជន
៤- លោក **សាយិដ ប្លាលគ** (Mr.SYED BALKHI) សប្បុរជន
៥- លោក **ខេម៉ារ៉ុន ស៊ីស្កូវិច** (Mr.CAMERON SISKOWIC) សប្បុរជន

៦- លោក **ប្រាយអិុន ឌីន** (Mr.BRIAN DEAN) សប្បុរជន

៧- លោក **នឹម ចន្ណា** ក្រុមការងារអនុវត្តគម្រោងអង្គការ CAMBODIAN VILLAGE FUND នៅកម្ពុជា

**មាត្រា ២**-. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..១៤.អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

## ការលុបឈ្មោះ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** លុបឈ្មោះ វរសេនីយ៍ឯក **ថាច់ ច័ន្ទតារា** អត្តលេខ០០២៥៩៦ ចេញពីក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

០៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ..៧៧៥..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះ ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-វរសេនីយ៍ទោ **សួស សារឿន** អត្តលេខ ០១៩៥៥០ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

២-វរសេនីយ៍ទោ **ស្រី ឈុន្នី** អត្តលេខ ០១៤៣៣១ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

៣-វរសេនីយ៍ទោ **អ៊ិន សុផល** អត្តលេខ ០១៤៣៤៤ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

៤-វរសេនីយ៍ទោ **សុខ សុខុន** អត្តលេខ ០០៨៥៦៣ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

៥-វរសេនីយ៍ទោ **ជា ណារ៉េត** អត្តលេខ ០១៤៣៤៣ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

៥

៦-វរសេនីយ៍ទោ **ប៉ាង សារឿន** អត្តលេខ ០១៩៥៥៧ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

៧-វរសេនីយ៍ទោ **ម៉ៃ យៀង** អត្តលេខ ០១៤៣៥០ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

៨-វរសេនីយ៍ទោ **គង់ រតនា** អត្តលេខ ០១៤៣៣០ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

៩-វរសេនីយ៍ទោ **គង់ ចាន់ស៊ីថា** អត្តលេខ ០១៤៣៥១ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

១០-វរសេនីយ៍ទោ **ឡុង ហៀប** អត្តលេខ ០៣១៧០៤ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

១១-វរសេនីយ៍ទោ **ហេង គៀង** អត្តលេខ ០១៩៥៤៩ នាយករង មន្ទីរពេទ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

១២-វរសេនីយ៍ទោ **សូត្រ តារា** អត្តលេខ ០២៥៣៨៨ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

១៣-វរសេនីយ៍ទោ **នី នាង** អត្តលេខ ០២៥៣៩១ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

១៤-វរសេនីយ៍ទោ **សៀម លីហាន** អត្តលេខ ០២៥៣៨៤ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

១៥-វរសេនីយ៍ទោ **សៀក តិច** អត្តលេខ ០៣១៤៧៤ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

១៦-វរសេនីយ៍ទោ **ណៃ ឧត្តម** អត្តលេខ ២២០៦៣៧ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

១៧-វរសេនីយ៍ទោ **នឹម សូត៉ា** អត្តលេខ ១០២៨១៤ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

១៨-វរសេនីយ៍ទោ **ពៅ សារ៉េន** អត្តលេខ ០២៥៣៨៦ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

១៩-វរសេនីយ៍ទោ **ខុន វណ្ណារ៉ាត់** អត្តលេខ ០១៩៩៨៥ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

២០-វរសេនីយ៍ទោ **មាស ឈុនលាត** អត្តលេខ ០៤៣២៤៧ យោធាចារ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

២១-វរសេនីយ៍ទោ **កង ចំរើន** អត្តលេខ ០៣១៤៥៩ នាយការិយាល័យបណ្តុះបណ្តាល មហាវិទ្យាល័យវេជ្ជសាស្ត្រ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

២២-វរសេនីយ៍ទោ **មុំ សុផល** អត្តលេខ ០៤៣២៨៤ នាយការិយាល័យធានាគុណភាពអប់រំផ្ទៃក្នុង វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

២៣-វរសេនីយ៍ទោ **សេង អរិយ្យធន** អត្តលេខ ០៣១៧៤៦ នាយករង មន្ទីរពេទ្យ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

២៤-វរសេនីយ៍ទោ **ឃិត ចាន់ឌី** អត្តលេខ ០២៥៤២៣ នាយករង មហាវិទ្យាល័យទន្តវេទសាស្ត្រ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

២៥-វរសេនីយ៍ទោ **ឃូ** **ថាវណា** អត្តលេខ ០៣១៧៦៤ នាយករង មហាវិទ្យាល័យវេជ្ជសាស្ត្រ
វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

២៦-វរសេនីយ៍ទោ **ចាន់** **ស៊ីណា** អត្តលេខ ០៣២០៥៧ នាយករង មហាវិទ្យាល័យទន្តវេទ
សាស្ត្រ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

២៧-វរសេនីយ៍ទោ **គង** **សាត** អត្តលេខ ០៣២១៩៤ យោធាចារ្យ
វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

២៨-វរសេនីយ៍ទោ **ឃឹម** **អូណែត**អត្តលេខ ០៧៧៦៨០ នាយការិយាល័យថែទាំអមវេជ្ជសាស្ត្រ
វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

២៩-វរសេនីយ៍ទោ **ឡាច** **ឌីតូ** អត្តលេខ ០២៨៤៣០ នាយករង មហាវិទ្យាល័យថែទាំ
អមវេជ្ជសាស្ត្រ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

៣០-វរសេនីយ៍ទោ **លឹម** **សៅ** អត្តលេខ ០១៩៩១៣ នាយករង មហាវិទ្យាល័យឱសថ
សាស្ត្រ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

៣១-វរសេនីយ៍ទោ **អុង** **វីរៈ** អត្តលេខ ២០៣៨៥៥ នាយការិយាល័យទំនាក់ទំនង
សាធារណៈ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

៣២-វរសេនីយ៍ទោ **សុខ** **ស៊ីណា** អត្តលេខ ០៣១៤៥៨ នាយករង មហាវិទ្យាល័យវេជ្ជសាស្ត្រ
វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

៣៣-វរសេនីយ៍ទោ **ឌឹម** **សុផា** អត្តលេខ ០៣៥៧១៧ នាយករង មហាវិទ្យាល័យថែទាំ
អមវេជ្ជសាស្ត្រ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

៣៤-វរសេនីយ៍ទោ **អុង** **គង់** អត្តលេខ ០៣១៥០៩ នាយករង មហាវិទ្យាល័យថែទាំអម
វេជ្ជសាស្ត្រ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីកសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៩៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១** : ផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **អ៊ុង ចាន់ធូក** អត្តលេខ ៧៣៥៥៧ ពីសមាជិកក្រុមប្រឹក្សានីតិកម្ម ទៅជាអនុប្រធានសេនាធិការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោកស្រី **អុខ សុតាវី** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៣ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្លាស់ប្តូរ និងតម្លើងឋានន្តរស័ក្តិមកជានាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ និងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិលោកស្រី **ទេត គឹមសុភារិទ្ធ** ពីឋានន្តរស័ក្តិក្រមការ ថ្នាក់លេខ៤ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ។

**មាត្រា ២** : ផ្លាស់ប្តូរ និងតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការចំនួន ០៣រូប មកជាឋានន្តរស័ក្តិនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានរាយនាមខាងក្រោមៈ

**ក.ក្រសួងមហាផ្ទៃ**

១-លោក **សុខ សារ៉ុម** ពីឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ថ្នាក់លេខ៩ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦

២-លោក **មិល ម៉ារឌី** ពីឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ថ្នាក់លេខ៩ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦

**ខ.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

៣-លោក **ស៊ូ ផល្លី** ពីឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ថ្នាក់លេខ១០ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៧ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង រៀបចំកិច្ចប្រជុំតុមូលចិនលើកទី៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការបញ្ជាប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១.**_

ត្រូវបានបង្កើត "គណៈកម្មការអន្តរក្រសួងរៀបចំកិច្ចប្រជុំតុមូលចិនលើកទី៥" ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ នៅខេត្តសៀមរាប ដូចមានសមាសភាពខាងក្រោមៈ

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២. រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣. រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៥. រដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ៦. រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧. រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨. រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៩. រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០. រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១១. រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២. រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១៣. រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ១៤. រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៥. រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ១៦. រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ១៧. រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៨. អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ១៩. អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ២០. មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២១. អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២២. អគ្គលេខាធិការរងគណៈកម្មការវិនិយោគ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២៣. អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២៤. អគ្គនាយក នៃអគ្គនាយដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ២៥. អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា | សមាជិក |
| ២៦. អភិបាល នៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ២៧. អគ្គលេខាធិការរង គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | សមាជិក |
| ២៨. ប្រធានមន្ទីរពាណិជ្ជកម្មខេត្តសៀមរាប | សមាជិក |

**ប្រការ ២.-**

គណៈកម្មការអន្តរក្រសួងរៀបចំកិច្ចប្រជុំតុមូលចិនលើកទី៥ មានភារកិច្ចដឹកនាំ ចាត់ចែង និងរៀបចំកិច្ចប្រជុំតុមូលចិនលើកទី៥ ឲ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។ គណៈកម្មការអន្តរក្រសួងនេះ អាចបង្កើតលេខាធិការដ្ឋាន អនុគណៈកម្មការ និងក្រុមការងារជំនាញដែលមានការចូលរួមដោយមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធ តាមការចាំបាច់។ លេខាធិការដ្ឋាន អនុគណៈកម្មការ និងក្រុមការងារជំនាញ ត្រូវបានបង្កើតឡើងដោយប្រកាសក្រសួងពាណិជ្ជកម្ម។

**ប្រការ ៣.**_

អនុប្រធាន និងសមាជិកនៃគណៈកម្មការអន្តរក្រសួងរៀបចំកិច្ចប្រជុំគុមូលចិនលើកទី៥ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានភារកិច្ចផ្សេង អនុប្រធានត្រូវដឹកនាំប្រជុំជំនួសតាមការប្រគល់ភារកិច្ចពីប្រធាន។ គណៈកម្មការអន្តរក្រសួងនេះ អាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន វិស័យឯកជន ឬភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់។

**ប្រការ ៤.**_

ការចំណាយសម្រាប់ដំណើរការរៀបចំកិច្ចប្រជុំគុមូលចិនលើកទី៥ ត្រូវយកពីថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងពាណិជ្ជកម្ម ឬថវិកាទទួលបានពីប្រភពស្របច្បាប់ផ្សេងទៀត។

**ប្រការ ៥.**_

គណៈកម្មការអន្តរក្រសួង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម ដើម្បីដំណើរការការងារ។

**ប្រការ ៦.**_

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ៧*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៣៣៦ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើតវង្វេរលោយប្រចាំទានសម្រាប់ឆ្នាំ២០១៧
# របស់អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/១៣៩៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នរ/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល មាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៥៤២ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ០០៥ សហវ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ ស្តីពីគោលការណ៍និងនីតិវិធីផ្ទៃក្នុងសម្រាប់ការអនុវត្តថវិកាកម្មវិធី របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១១៤៤ សហវ.ប្រក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីការតែងតាំងរជ្ជទេយ្យបុរេប្រទាន និងរជ្ជទេយ្យបុរេប្រទានរង របស់អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និង នីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៥៦៩ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន ជំពូក៦០"ការទិញ" ជំពូក៦១"សេវាកម្ម" នៅអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២.-**

ចំនួនទឹកប្រាក់មួយដុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានរតនាគារជាតិ

## តារាងឧបសម្ព័ន្ធនៃលទ្ធផលប្រើប្រាស់ឥណទានថវិកាកម្មវិធីតាមចំណាត់ថ្នាក់សេដ្ឋកិច្ចឆ្នាំ ២០១៧
## របស់អគ្គនាយកដ្ឋានរតនាគារជាតិ

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៧ | ឥណទាន ដែលត្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | **សរុបរួម** | 6,239,500,000 | 5,132,000,000 | 2,545,924,000 | 2,586,076,000 | 636,481,000 | 49.6% |
| 60 | | | ការទិញ | 2,975,000,000 | 2,198,700,000 | 502,724,000 | 1,695,976,000 | 125,681,000 | 22.9% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 534,300,000 | 534,300,000 | 232,100,000 | 302,200,000 | 58,025,000 | 43.4% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 165,400,000 | 165,400,000 | 65,400,000 | 100,000,000 | 16,350,000 | 39.5% |
| | | 60012 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ | 69,300,000 | 69,300,000 | 4,300,000 | 65,000,000 | 1,075,000 | 6.2% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈ ឧបករណ៍ | 202,400,000 | 202,400,000 | 132,400,000 | 70,000,000 | 33,100,000 | 65.4% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 97,200,000 | 97,200,000 | 30,000,000 | 67,200,000 | 7,500,000 | 30.9% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 688,300,000 | 668,300,000 | 152,210,000 | 516,090,000 | 38,052,500 | 22.8% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 668,300,000 | 668,300,000 | 152,210,000 | 516,090,000 | 38,052,500 | 22.8% |
| | | 60022 | សៀវភៅមើលនិងឯកសារ | 20,000,000 | - | - | - | - | 0.0% |
| | 6004 | | សំលៀកបំពាក់និងការតុបតែង | 12,000,000 | 12,000,000 | 12,000,000 | - | 3,000,000 | 100.0% |
| | | 60048 | សំលៀកបំពាក់និងការតុបតែងផ្សេងៗ | 12,000,000 | 12,000,000 | 12,000,000 | - | 3,000,000 | 100.0% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 984,100,000 | 984,100,000 | 106,414,000 | 877,686,000 | 26,603,500 | 10.8% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 826,300,000 | 826,300,000 | 65,014,000 | 761,286,000 | 16,253,500 | 7.9% |
| | | 60052 | សង្ហារឹម | 73,800,000 | 73,800,000 | 19,400,000 | 54,400,000 | 4,850,000 | 26.3% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 75,800,000 | 75,800,000 | 13,800,000 | 62,000,000 | 3,450,000 | 18.2% |
| | | 60054 | សម្ភារៈនិងឧបករណ៍ដឹកជញ្ជូន | 8,200,000 | 8,200,000 | 8,200,000 | - | 2,050,000 | 100.0% |
| | 6006 | | ថាមពលនិងទឹក | 756,300,000 | - | - | - | - | 0.0% |
| | | 60061 | អគ្គិសនី | 657,000,000 | | - | - | - | 0.0% |
| | | 60062 | ទឹក | 99,300,000 | | - | - | - | 0.0% |
| 61 | | | សេវាកម្ម | 3,264,500,000 | 2,933,300,000 | 2,043,200,000 | 890,100,000 | 510,800,000 | 69.7% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៧ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ត្រង់ | ឥណទាន០១ត្រីមាស រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | 6103 | | ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម) | 88,800,000 | | - | - | - | 0.0% |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុងនិងក្រៅប្រទេស | 64,300,000 | 64,300,000 | 64,300,000 | - | 16,075,000 | 100.0% |
| | 6105 | | ការថែទាំនិងជួសជុល | 1,212,400,000 | 1,212,400,000 | 425,100,000 | 787,300,000 | 106,275,000 | 35.1% |
| | | 61052 | ការថែទាំ ជួសជុលអាគារផ្សេងៗ និងប្រាសាទ | 538,300,000 | 538,300,000 | 76,000,000 | 462,300,000 | 19,000,000 | 14.1% |
| | | 61053 | ការថែទាំនិងជួសជុល ផ្លូវ ផ្លូវលំ ស្ពាន និងលូ | 172,000,000 | 172,000,000 | 72,000,000 | 100,000,000 | 18,000,000 | 41.9% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 148,300,000 | 148,300,000 | 83,300,000 | 65,000,000 | 20,825,000 | 56.2% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 48,000,000 | 48,000,000 | 48,000,000 | - | 12,000,000 | 100.0% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈនិងឧបករណ៍បច្ចេកទេស | 305,800,000 | 305,800,000 | 145,800,000 | 160,000,000 | 36,450,000 | 47.7% |
| | 6107 | | សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃ | 38,000,000 | - | - | - | - | 0.0% |
| | | 61073 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | 38,000,000 | | - | - | - | 0.0% |
| | 6108 | | សោហ៊ុយដឹកជញ្ជូន | 9,600,000 | 9,600,000 | 9,600,000 | - | 2,400,000 | 100.0% |
| | | 61081 | សម្ភារៈនិងទំនិញ | 9,600,000 | 9,600,000 | 9,600,000 | - | 2,400,000 | 100.0% |
| | 6109 | | បុគ្គលិកខាងក្រៅ | 22,200,000 | 22,200,000 | 22,200,000 | - | 5,550,000 | 100.0% |
| | | 61098 | បុគ្គលិកខាងក្រៅផ្សេងៗ | 22,200,000 | 22,200,000 | 22,200,000 | - | 5,550,000 | 100.0% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 291,800,000 | 291,800,000 | 211,800,000 | 80,000,000 | 52,950,000 | 72.6% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 80,000,000 | 80,000,000 | 80,000,000 | - | 20,000,000 | 100.0% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 4,000,000 | 4,000,000 | 4,000,000 | - | 1,000,000 | 100.0% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 70,500,000 | 70,500,000 | 70,500,000 | - | 17,625,000 | 100.0% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 100,000,000 | 100,000,000 | 20,000,000 | 80,000,000 | 5,000,000 | 20.0% |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍នៅក្នុងនិងក្រៅប្រទេស | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| | | 61108 | សោហ៊ុយទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយផ្សេងៗ | 35,300,000 | 35,300,000 | 35,300,000 | - | 8,825,000 | 100.0% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 1,200,300,000 | 1,200,300,000 | 1,177,500,000 | 22,800,000 | 294,375,000 | 98.1% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 254,600,000 | 254,600,000 | 254,600,000 | - | 63,650,000 | 100.0% |
| | | 61122 | សោហ៊ុយបេសកកម្ម | 142,600,000 | 142,600,000 | 142,600,000 | - | 35,650,000 | 100.0% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 803,100,000 | 803,100,000 | 780,300,000 | 22,800,000 | 195,075,000 | 97.2% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 50,100,000 | 50,100,000 | 50,100,000 | - | 12,525,000 | 100.0% |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 9,600,000 | 9,600,000 | 9,600,000 | - | 2,400,000 | 100.0% |
| | | 61132 | សោហ៊ុយបេសកកម្ម | 10,500,000 | 10,500,000 | 10,500,000 | - | 2,625,000 | 100.0% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៧ | ឥណទាន ដែលស្នើសុំ | ឥណទាន រជ្ជទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ត្រង់ | ឥណទាន០១ដំបូង រជ្ជទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | 61133 | សោហ៊ុយស្នាក់នៅ | 30,000,000 | 30,000,000 | 30,000,000 | - | 7,500,000 | 100.0% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 204,400,000 | - | - | - | - | 0.0% |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 7,600,000 | | - | - | - | 0.0% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 196,800,000 | | - | - | - | 0.0% |
| | 6198 | | សោហ៊ុយនិងសេវាកម្មផ្សេងៗ | 82,600,000 | 82,600,000 | 82,600,000 | - | 20,650,000 | 100.0% |

បានឃើញនិងពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៧
ស. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង
ម៉ិញ បានសុវណ្ណអាធិប្បាសីលា

បានឃើញនិងពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ០១ ឆ្នាំ ២០១៧
ជ. អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
គីម ចំរើន

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១៧
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញនិងពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៦
អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
បណ្ឌិត ម៉ៅ ប៊ុនឥន្ទ្រារ៉ូទ្ធ

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៦
រដ្ឋលេខាធិការប្រចាំការ
ទិត សុទី

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..១០៦......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតនិងតែងតាំងក្រុមលទ្ធកម្ម នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធី នៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ. បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសារធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការ អង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិការកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាស ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៥៦៩ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ ជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតនិងតែងតាំងក្រុមលទ្ធកម្មនៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **គុណ ញឹម** | អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | ជាប្រធាន |
| ២. លោក **ហ៊ឹង គីមហេង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | ជាអនុប្រធាន |
| ៣. លោក **ខៀវ សំអាន** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង | ជាសមាជិក |
| ៤. លោក **សុខ ទ្រី** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង | ជាសមាជិក |
| ៥. លោក **ជា សំអុន** | ប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៦. លោកស្រី **ឆន់ ពុទ្ធីមាន** | អនុប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ | ជាសមាជិក។ |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាមីអង្គភាពថវិកា
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០៣៦ ព.ណ.គិន.ប្រក

# ប្រកាស
# ស្តីពី
# ការតែងតាំងអាណាប័កផ្ទេរសិទ្ធិ និងការផ្ទេរឥណទានថវិកា

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ២៦៣ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧

## សម្រេច

**ប្រការ១** :

| | | |
|---|---|---|
| ឯកឧត្តម | **គីម ស៊ីថន** | រដ្ឋលេខាធិការ |
| លោកជំទាវ | **តឹករ៉េត កំរង** | រដ្ឋលេខាធិការ |
| ឯកឧត្តម | **អ៊ុក ធី** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ |
| លោក | **គីម ច័ន្ទរស្មី** | ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ |

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA* *Phone/Facsimile: (855)-23 866 469*

ត្រូវទទួលបន្ទុកជាអាណាប័កផ្ទេរសិទ្ធិ ក្នុងការគ្រប់គ្រងឥណទានថវិកាឆ្នាំ២០១៧ របស់ក្រសួងពាណិជ្ជកម្ម ថ្នាក់កណ្តាល។

**ប្រការ២** :

ឥណទានថវិការបស់ក្រសួងពាណិជ្ជកម្ម ថ្នាក់រដ្ឋបាលកណ្តាល សម្រាប់ចំណាយក្នុងឆ្នាំ២០១៧ មានទឹកប្រាក់ចំនួន ១១២.៩៣២.៣០០.០០០រៀល (មួយរយដប់ពីរប៊ីលាន ប្រាំបួនរយសាមសិបពីរលាន បីរយពាន់រៀលគត់) ត្រូវបានបែងចែកតាមក្រុម ប្រភេទ ជំពូក គណនី អនុគណនី ដូចមានក្នុងសៀវភៅថវិកាកម្មវិធីដែលភ្ជាប់ជូននឹងប្រកាសនេះ។

**ប្រការ៣** :

